ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ព្រឹត្តិបត្រប្រចាំឆមាស

# BULLETIN SEMESTRIEL
# SEMESTERLY BULLETIN

## ទីស្ដីការគណៈរដ្ឋមន្ត្រី
## គណៈកម្មាធិការជាតិភាសាខ្មែរ

លេខ ១ ឆមាសទី១ ឆ្នាំ២០០៨ VOL. 1, SEMESTER 1, 2008

លេខាធិការដ្ឋានអចិន្ត្រៃយ៍ : វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា (ជាន់ទី២)
Secrétariat permanent: Institut de la Langue Nationale de l'Academie Royale du Cambodge
Permanent Secretariat: National Language Institute of the Royal Academy of Cambodia
Tel: 012 911 357 / 016 947 421/ FAX: 023 983 871 / E-mail: nckl_secretariat@yahoo.com

## គណៈគ្រប់គ្រង

-ប្រធាន : ឯកឧត្តមបណ្ឌិត **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ជាប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ

-អនុប្រធានអចិន្ត្រៃយ៍ : ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ព្រុំ ម៉ល់**

-អនុប្រធាន : ឯកឧត្តម **ឈន អៀម**

-អគ្គលេខាធិការ : ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ស៊ុំ ឈុំប៊ុន**

-អគ្គលេខាធិការរង : ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **អ៊ីវ ច័ន**

## ក្រុមការងារ

### ១-ក្រុមអ្នកចាត់ការទូទៅ

-លោកសាស្ត្រាចារ្យ **ស៊ុំ ឈុំឡុង** ប្រធានការិយាល័យបោះពុម្ពផ្សាយ

-លោកសាស្ត្រាចារ្យ **សន ពៅ** ប្រធានការិយាល័យហិរញ្ញវត្ថុ

-លោកសាស្ត្រាចារ្យ **ជួរ គារី** ប្រធានការិយាល័យរដ្ឋបាល

### ២-ក្រុមអ្នករៀបចំ

-លោកសាស្ត្រាចារ្យ **សេ អឿន** អនុប្រធានការិយាល័យបោះពុម្ពផ្សាយ

-លោកសាស្ត្រាចារ្យ **ប៊ី សុខគង់** អនុប្រធានការិយាល័យបោះពុម្ពផ្សាយ

-លោកសាស្ត្រាចារ្យ **ឡុង សុរិន្ទ** សមាជិកការិយាល័យបោះពុម្ពផ្សាយ

-លោកស្រីសាស្ត្រាចារ្យ **តិប ស៊ីណា** សមាជិកការិយាល័យបោះពុម្ពផ្សាយ

# មាតិកា

ទំព័រ


-បុព្វកថា........................................................................................................ i

-អារម្ភកថា....................................................................................................... ii

-សាវតារ និង បុព្វហេតុនៃការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ........................................ ១

-អនុក្រឹត្យស្ដីពីការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ...................................................... ៤

-អនុក្រឹត្យស្ដីពីការកែសម្រួលសមាសភាពនៃគណៈកម្មាធិការជាតិភាសាខ្មែរ................................ ៩

-បទបញ្ជាផ្ទៃក្នុងនៃគណៈកម្មាធិការជាតិភាសាខ្មែរ................................................................ ១១

-សេចក្ដីសម្រេចស្ដីពីការបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិភាសាខ្មែរ...................... ១៤

-សេចក្ដីសម្រេចស្ដីពីការបង្កើតគណៈកម្មការបច្ចេកទេសនៃគណៈកម្មាធិការជាតិភាសាខ្មែរ........................ ១៧

-សេចក្ដីសម្រេចស្ដីពីការបង្កើតគណៈកម្មការអាដហុក ដើម្បីពិនិត្យ និង ផ្ដល់យោបល់លើសៀវភៅ វេយ្យាករណ៍ភាសាខ្មែរ របស់លោកសាស្ត្រាចារ្យបណ្ឌិត ឃីន សុខ........................................ ២៣

-កម្មវិធីសិក្ខាសាលាស្ដីពី "ការរៀបចំដំណើរការនៃគណៈកម្មាធិការជាតិភាសាខ្មែរ" ................................ ២៥

-សុន្ទរកថារបស់ឯកឧត្ដមសាស្ត្រាចារ្យបណ្ឌិត ស៊ន សំណាង ប្រធានរាជបណ្ឌិតសភាកម្ពុជា និង ជាទីប្រឹក្សា គណៈកម្មាធិការជាតិភាសាខ្មែរ ក្នុងឱកាសបើកសិក្ខាសាលា ស្ដីពី "ការរៀបចំដំណើរការនៃគណៈកម្មាធិការ ជាតិភាសាខ្មែរ" ........................................................................................ ២៨

-សុន្ទរកថារបស់ឯកឧត្ដមសាស្ត្រាចារ្យបណ្ឌិត ព្រុំ ម៉ល់ អនុប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ ក្នុងឱកាស បិទសិក្ខាសាលា ស្ដីពី "ការរៀបចំដំណើរការនៃគណៈកម្មាធិការជាតិភាសាខ្មែរ" .................................. ៣១

-របាយការណ៍បូកសរុបខ្លឹមសារសិក្ខាសាលាស្ដីពី "ការរៀបចំដំណើរការនៃគណៈកម្មាធិការជាតិភាសាខ្មែរ"... ៣៣

-កម្មវិធីសិក្ខាសាលាស្ដីពី"ការរៀបចំដំណើរការគណៈកម្មការបច្ចេកទេសនៃគណៈកម្មាធិការជាតិភាសាខ្មែរ" . ៣៩

-សុន្ទរកថារបស់លោកជំទាវសាស្ត្រាចារ្យបណ្ឌិត ខ្លូត ធីតា អនុប្រធានរាជបណ្ឌិតសភាកម្ពុជា និង ជាសមាជិក គណៈកម្មាធិការជាតិភាសាខ្មែរ និង ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្ដមសាស្ត្រាចារ្យបណ្ឌិត ស៊ន សំណាង ប្រធាន រាជបណ្ឌិតសភាកម្ពុជា និង ជាទីប្រឹក្សាគណៈកម្មាធិការជាតិភាសាខ្មែរ ក្នុងពិធីបើកសិក្ខាសាលា ស្ដីពី "ការរៀបចំ ដំណើរការគណៈកម្មការបច្ចេកទេសនៃ គណៈកម្មាធិការជាតិភាសាខ្មែរ"............................................ ៤១

-សុន្ទរកថារបស់ឯកឧត្ដមសាស្ត្រាចារ្យបណ្ឌិត ព្រុំ ម៉ល់ អនុប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ ក្នុងឱកាសបិទ សិក្ខាសាលា ស្ដីពី "ការរៀបចំដំណើរការគណៈកម្មការបច្ចេកទេសនៃគណៈកម្មាធិការជាតិភាសាខ្មែរ" ........ ៤៣

-របាយការណ៍បូកសរុបខ្លឹមសារសិក្ខាសាលាស្ដីពី "ការរៀបចំដំណើរការគណៈកម្មការបច្ចេកទេសនៃគណៈកម្មាធិការ ជាតិភាសាខ្មែរ" ........................................................................................ ៤៦

-សារាចរណែនាំស្ដីពីការប្រើប្រាស់អក្ខរាវិរុទ្ធក្នុងលិខិតស្នាមផ្លូវការរបស់ក្រសួងអប់រំ យុវជន និង កីឡា......... ៥៣

-សេចក្ដីសម្រេចសំខាន់ៗនៃគណៈកម្មាធិការជាតិភាសាខ្មែរ.................................................... ៥៤

# បុព្វកថា

យើងទាំងអស់គ្នាបានដឹងមកហើយថា សង្គ្រាមស៊ីវិលនិងការផ្លាស់ប្តូររបបគ្រប់គ្រងរដ្ឋជាបន្តបន្ទាប់ បាននាំមកនូវផលប៉ះពាល់ជាច្រើនដល់សង្គមនិងវប្បធម៌ខ្មែរ ។ ពាក្យមួយចំនួននៃភាសាខ្មែរត្រូវបានគេសរសេរប្លែកពីមុន ចាប់ពីឆ្នាំ១៩៧០ ហើយ កង្វះឯកភាព ក្នុងការប្រើពាក្យ ក្នុងការអានពាក្យ និង ក្នុងការខ្ចីពាក្យពីភាសាបរទេស ក៏កើតមានឡើងជាបន្តបន្ទាប់ ។

អ្នកស្រឡាញ់ភាសាជាតិតែងតែចង់ឱ្យមានគណៈកម្មាធិការមួយ ជាពិសេស តាមរយៈអនុសាសន៍នៃសន្និសីទទាំងបីលើករៀបចំឡើងដោយវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា ដើម្បីឱ្យស្វែងរកឯកភាពជូនភាសាយើងវិញ ។

រាជរដ្ឋាភិបាលមិនបានព្រងើយកន្តើយនឹងបញ្ហានេះទេ ។ ក្រោយពីបានសង់ឡើងវិញជាអាទិភាពទី១ នូវហេដ្ឋារចនាសម្ព័ន្ធបំផ្លាញដោយសង្គ្រាម សម្តេចអគ្គមហាសេនាបតី តេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានចេញអនុក្រឹត្យ លេខ១៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៧ បង្កើត **គណៈកម្មាធិការជាតិភាសាខ្មែរ** ដែលត្រូវជាជំហានដំបូង ស្វែងរកឯកភាពជូនភាសាយើង ហើយ ជាបន្តបន្ទាប់ត្រូវធ្វើឱ្យភាសានេះក្លាយទៅជាអរិយភាសា ដូច ភាសាអង់គ្លេស ភាសាបារាំង ជាដើម ។

យើងបានសង្កេតឃើញថា **គណៈកម្មាធិការជាតិភាសាខ្មែរ** បានដោះស្រាយបញ្ហាបានមួយចំនួនហើយ និង កំពុងខំដោះស្រាយតទៀតនូវបញ្ហាដែលនៅមាន ។ ខ្ញុំសង្ឃឹមថា គណៈកម្មាធិការនេះនឹងមានដំណើរការល្អតទៅទៀត និង សម្រេចកិច្ចការរបស់ខ្លួនដោយជោគជ័យតទៅទៀត ដើម្បីជាប្រយោជន៍ ដល់ភាសាជាតិ និង ដល់ប្រទេសជាតិទាំងមូល ។

រាជធានីភ្នំពេញ ថ្ងៃទី 05 ខែកក្កដា ឆ្នាំ២០០៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**និង ជាប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ**

**សុខ អាន**

# <u>អារម្ភកថា</u>

ដូចឯកឧត្តមបណ្ឌិត **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ជាប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ.) បានបញ្ជាក់ក្នុងបុព្វកថារួចមកហើយ គ.ជ.ភ.ខ.យើងមានភារកិច្ច ជាជំហានដំបូង ស្វែងរកឯកភាពលើបួនចំណុចជូនភាសាយើងវិញ ក្រោយពីកង្វះឯកភាពត្រូវបានកើតមានឡើង បន្ទាប់ពីមានសង្គ្រាមស៊ីវិលនិងមានការផ្លាស់ប្តូររបបគ្រប់គ្រងរដ្ឋជាបន្តបន្ទាប់ : កង្វះឯកភាពលើបួនចំណុចនោះ គឺកង្វះឯកភាព ក្នុងការសរសេរពាក្យមួយចំនួន ក្នុងការប្រើពាក្យមួយចំនួន ក្នុងការអានពាក្យមួយចំនួន និង ក្នុងការខ្ចីពាក្យមួយចំនួនពីភាសាបរទេស ។

ដោយមានសម្បទានពីសមាជិករបស់ខ្លួនមួយចំនួន គ.ជ.ភ.ខ.បានអនុម័តជាឯកច្ឆន្ទ យកវចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត ជាមូលដ្ឋាន មានអក្ខរាវិរុទ្ធជាពិសេស ។ គ.ជ.ភ.ខ.កំពុងខំស្វែងរកឯកភាពលើបីចំណុចទៀត ។ បន្ទាប់តទៅ គ.ជ.ភ.ខ.នឹងខំបំពេញភារកិច្ចថ្មីរបស់ខ្លួន ដូចដែលឯកឧត្តមប្រធានបានចង្អុលបង្ហាញផងដែរក្នុងបុព្វកថារបស់លោក ។ យើងត្រូវធ្វើយ៉ាងណាឱ្យភាសាខ្មែរមានសទ្ទានុក្រមផ្លូវការសម្រាប់ជំនាញនីមួយៗ ដើម្បីឱ្យអ្នកជំនាញមួយក្រុមៗប្រើវាក្យស័ព្ទដូចៗគ្នា ។

ក្នុងការស្វែងរកឯកភាព គ.ជ.ភ.ខ.ត្រូវជ្រើសរើសយកពាក្យណាដែលមានប្រើមុនគេ លើកលែងតែពាក្យនោះមានបញ្ហាបែបណាមួយ ។ ក្នុងស្មារតីនេះ គ.ជ.ភ.ខ.បានតាមដាន ពិនិត្យពាក្យដែលគេប្រើនៅបឋមសិក្សានិងនៅមធ្យមសិក្សា ដោយធ្វើការស្រាវជ្រាវ តាមមូលដ្ឋានផង និង តាមឯកសារផង ជាពិសេស តាមសទ្ទានុក្រមខេមរយានកម្ម ។

ភារកិច្ចរបស់ គ.ជ.ភ.ខ.មិនអាចបញ្ចប់ក្នុងរយៈពេលខ្លីបានទេ ពីព្រោះ ដូចយើងបានឃើញខាងលើស្រាប់ ភារកិច្ចនេះជាកិច្ចការធំធេងណាស់ក៏ផង និង ពីព្រោះ សមាជិកនៃ គ.ជ.ភ.ខ.យើងនេះ ស឵ឹងសុទ្ធជាឥស្សរជនដែលធ្វើការបន្ថែមម៉ោងលើបន្ទុករបស់គេក្នុងឋានៈគេជាមន្ត្រីរាជការក៏ផង ។

យើងសង្ឃឹមថា កិច្ចការរបស់ គ.ជ.ភ.ខ.នឹងបានលទ្ធផលសមស្របតាមលក្ខណៈរបស់ភាសាខ្មែរ និងប្រកបដោយកម្មវិស័យភាពនិងគុណភាពខ្ពស់ ពីព្រោះ ទាំងសមាជិកនៃ គ.ជ.ភ.ខ.ផ្ទាល់ ទាំងសមាជិកនៃគណៈកម្មការបច្ចេកទេសរបស់ខ្លួន សុទ្ធតែជាអ្នកមានចំណេះជ្រៅជ្រះ ។

ម្យ៉ាងទៀត យើងមិនអាចលើកឡើងតែបញ្ហាបច្ចេកទេសសុទ្ធសាធ ដោយមិននិយាយពីបញ្ហាហិរញ្ញវត្ថុនោះទេ ។ គ.ជ.ភ.ខ.មិនអាចដំណើរការបាន ដោយឥតមានការគាំទ្រខាងហិរញ្ញវត្ថុពីសំណាក់រាជរដ្ឋាភិបាលបានឡើយ ។

ក្នុងនាមសមាជិកនៃ គ.ជ.ភ.ខ. សមាជិកនៃគណៈកម្មការបច្ចេកទេសទាំងប្រាំបី ព្រមទាំងសមាជិកនៃលេខាធិការដ្ឋានអចិន្ត្រៃយ៍ផង ខ្ញុំសូមសំដែងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ និង ថ្លែងអំណរគុណដោយស្មោះអស់ពីដួងចិត្ត ជូនសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ដែលបានឧបត្ថម្ភគាំទ្រ តាមរយៈឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ជាប្រធាននៃគណៈកម្មាធិការជាតិភាសាខ្មែរ ឱ្យគណៈកម្មាធិការនេះមានឱកាសសម្រាប់ដំណើរការ ។

ក្នុងឱកាសស្របគ្នានេះ និង ក្នុងនាមឥស្សរជនដែលខាងលើ ខ្ញុំសូមសំដែងនូវគារវភក្តី ជូនឯកឧត្តម **សុខ អាន** ក្នុងឋានៈឯកឧត្តមជាប្រធាននៃគណៈកម្មាធិការជាតិភាសាខ្មែរ ដោយឯកឧត្តមតែងតែយកចិត្តទុកដាក់ណែនាំយើងខ្ញុំជានិច្ចកាល ទោះឯកឧត្តមមានកិច្ចការមមាញឹកក្នុងរាជរដ្ឋាភិបាលក៏ដោយ ។

រាជធានីភ្នំពេញ ថ្ងៃទី 07 ខែកក្កដា ឆ្នាំ២០០៨

**អនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិភាសាខ្មែរ**

**បណ្ឌិត ព្រុំ ម៉ល់**

# សារធារ និង បុព្វហេតុនៃការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ

## I-**សារធារ** :

ភាសាខ្មែរយើងបានរីកចម្រើនខ្លាំងនៅពេល ដែលវចនានុក្រមខ្មែរត្រូវបានបោះពុម្ពផ្សាយជាលើកដំបូងនៅឆ្នាំ១៩៣៨ ដោយព្រះមហាក្សត្រខ្មែរបានបង្កើតក្រុមជំនុំមួយនៅឆ្នាំ១៩១៥ ឱ្យធ្វើវចនានុក្រមខ្មែរនេះ ដែលមានសម្តេចព្រះសង្ឃរាជ **ជួន ណាត** ជាអ្នកទទួលខុសត្រូវនៅរយៈពេលចុងក្រោយ។ នៅឆ្នាំ១៩៣៤ ព្រះមហា-ក្សត្រខ្មែរបានបង្កើតក្រុមជំនុំមួយទៀត ដែលក្រោយមកត្រូវគេហៅថា **"គណៈកម្មការវប្បធម៌"** គឺគណៈកម្មការនេះហើយជាអ្នកបង្កើតបច្ចេកស័ព្ទថ្មីៗ ដែលពេលនោះគេហៅថា **"ពាក្យវប្បធម៌"** ដូចជា ពាក្យ ***"រដ្ឋាភិបាល"***, ***"ធនាគារ"*** ជាដើម។ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រទី៣ក្នុងការរីកចម្រើនភាសាខ្មែរ គឺការបង្កើតគណៈកម្មការជាតិខេមរយានកម្ម នៅឆ្នាំ១៩៦៧ ដែលមានសម្តេចព្រះសង្ឃរាជ **ជួន ណាត** ជាព្រះប្រធាន និង ប្រធាននៃគណៈ-កម្មការបច្ចេកស័ព្ទនៃមុខវិជ្ជានានាជាសមាជិក។ នៅពេលនោះ បច្ចេកស័ព្ទត្រូវទទួលការអនុម័តសិន មុននឹងយកទៅប្រើប្រាស់ក្នុងការបង្រៀន។

ដោយមានសង្គ្រាមស៊ីវិល និង ដោយប្រទេសកម្ពុជាត្រូវបានកាន់កាប់ដោយរបបខ្មែរក្រហម គណៈ-កម្មការជាតិខេមរយានកម្មត្រូវរលត់រលាយទៅ ហើយក្រោយមក ការបង្កើតពាក្យពុំត្រូវបានគ្រប់គ្រងដូចសម័យសម្តេចព្រះសង្ឃរាជ **ជួន ណាត** ឡើយ។ សព្វថ្ងៃនេះ ខ្មែរណាក៏ដឹងដែរថា ភាសាយើងខ្វះឯកភាពទាំងក្នុងការសរសេរពាក្យ និង ទាំងក្នុងការអានពាក្យមួយចំនួន ទាំងក្នុងការបង្កើតពាក្យ ទាំងក្នុងការខ្ចីពាក្យពីភាសាបរទេស។

ដោយខ្វះឯកភាពដូចនេះ វិទ្យាស្ថានភាសាជាតិបានរៀបចំសិក្ខាសាលាស្តីពីការស្រាវជ្រាវ ឯកភាព និង អភិវឌ្ឍន៍ភាសាខ្មែរ លើកទី១ នៅឆ្នាំ២០០០ និង លើកទី២ នៅឆ្នាំ២០០៥។

## II- **ការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ** :

យោងតាមអនុសាសន៍របស់សមាជិក សមាជិកានៃអង្គសិក្ខាសាលាទាំងពីរលើករបស់វិទ្យាស្ថានភាសាជាតិបានស្នើសុំឱ្យរាជរដ្ឋាភិបាលបង្កើត **"គណៈកម្មាធិការជាតិភាសាខ្មែរ"** មួយឡើង។ នៅក្នុងពិធីបិទសិក្ខាសាលាលើកទី៣ របស់វិទ្យាស្ថានភាសាជាតិ ឆ្នាំ២០០៦ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** អញ្ជើញមកជាអធិបតីបិទសិក្ខាសាលានេះ ក្នុងនាមឯកឧត្តមជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** និង ក្នុងនាមរាជរដ្ឋា-ភិបាលកម្ពុជា ឯកឧត្តមអនុញ្ញាតឱ្យបង្កើត **"គណៈកម្មាធិការជាតិភាសាខ្មែរ"** នេះឡើង។

**"គណៈកម្មាធិការជាតិភាសាខ្មែរ"** ត្រូវបានបង្កើតឡើងតាមរយៈអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៧ ដែលមានសមាជិកចំនួន៤០រូប។ គណៈកម្មាធិការនេះមានភារកិច្ចរកឯកភាពក្នុងការសរសេរការអាន ការបង្កើតពាក្យថ្មី និង កម្ចីពាក្យពីបរទេស។

ដើម្បីអនុវត្តភារកិច្ច និង គោលដៅរបស់ខ្លួនបានជោគជ័យ គណៈកម្មាធិការជាតិភាសាខ្មែរបានបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍ និង បង្កើតគណៈកម្មការបច្ចេកទេសចំនួន០៨ ដូចខាងក្រោម :

## ១.លេខាធិការដ្ឋានអចិន្ត្រៃយ៍ :

លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិភាសាខ្មែរត្រូវបានបង្កើតឡើងតាមរយៈសេចក្ដីសម្រេចលេខ ១២១ សសរ. ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ ដែលមានភារកិច្ចជាអង្គភាពជំនួយការឱ្យគណៈ-កម្មាធិការជាតិភាសាខ្មែរ។

លេខាធិការដ្ឋានអចិន្ត្រៃយ៍នេះមានសមាសភាពចំនួន១៥រូប និង មាន០៣ការិយាល័យ គឺ :

**១.១.ការិយាល័យរដ្ឋបាល :** មានសមាសភាពចំនួន៥រូប ក្នុងនោះមានប្រធាន១រូប អនុប្រធាន២រូប និង សមាជិក២រូប)។

**១.២.ការិយាល័យហិរញ្ញវត្ថុ :** មានសមាសភាពចំនួន៥រូប ក្នុងនោះមានប្រធាន១រូប អនុប្រធាន២រូប និង សមាជិក២រូប)។

**១.៣.ការិយាល័យបោះពុម្ពផ្សាយ :** មានសមាសភាពចំនួន៥រូប ក្នុងនោះមានប្រធាន១រូប អនុប្រធាន២រូប និង សមាជិក២រូប)។

## ២.ការបង្កើតគណៈកម្មការបច្ចេកទេស :

គណៈកម្មការបច្ចេកទេសទាំង០៨បានបង្កើតឡើងតាមសេចក្ដីសម្រេចលេខ ១២៣ សសរ. ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ ដែលមានសមាសភាពសរុបចំនួន៦២រូប ហើយមានមុខងារ និង ភារកិច្ចដូចតទៅ :

### ២.១.គណៈកម្មការអក្ខរាវិរុទ្ធ និង អំណាន :

គណៈកម្មការអក្ខរាវិរុទ្ធ និង អំណានមានសមាសភាពចំនួន១១រូប ក្នុងនោះមានប្រធាន១រូប អនុប្រធាន១រូប ទីប្រឹក្សា១រូប សមាជិក៧រូប និង លេខាធិការ១រូប។

ភារកិច្ចរបស់គណៈកម្មការនេះគឺប្រមូលពាក្យ និង កំណត់ការអានពាក្យនៅក្នុងភាសាខ្មែរ ដែលមានបញ្ហានាពេលបច្ចុប្បន្ននេះ ក្នុងគោលបំណងស្វែងរកឯកភាពនៃការសរសេរពាក្យ និង ការអានពាក្យ ដើម្បីដាក់ជូនគណៈកម្មាធិការជាតិភាសាខ្មែរអនុម័ត។

### ២.២.គណៈកម្មការនៃការបង្កើតពាក្យ និង កម្ចីពាក្យ :

គណៈកម្មការនៃការបង្កើតពាក្យ និង កម្ចីពាក្យមានសមាសភាពចំនួន១១រូប ក្នុងនោះមានប្រធាន១រូប អនុប្រធាន១រូប សមាជិក៨រូប និង លេខាធិការ១រូប។

ភារកិច្ចរបស់គណៈកម្មការនេះគឺកំណត់គោលការណ៍ក្នុងការបង្កើតពាក្យ និង កម្ចីពាក្យ ក្នុងគោលបំណងស្វែងរកឯកភាពនៃការបង្កើតពាក្យ និង កម្ចីពាក្យ ដើម្បីដាក់ជូនគណៈកម្មាធិការជាតិភាសាខ្មែរអនុម័ត។

ចំពោះគណៈកម្មការបច្ចេកស័ព្ទទាំង៦ខាងក្រោមនេះ គណៈកម្មការនីមួយៗមានភារកិច្ចប្រមូលវាក្យស័ព្ទមានប្រើរួចមកហើយ ដែលមានបញ្ហាមិនឯកភាពគ្នា និង បង្កើតពាក្យថ្មីបន្ថែមទៀត តាមមុខវិជ្ជារៀងៗខ្លួន ដើម្បីស្វែងរកឯកភាពក្នុងការសរសេរ ការអាន និង ការបង្កើតបច្ចេកស័ព្ទថ្មីៗ ដាក់ជូនគណៈកម្មាធិការជាតិភាសាខ្មែរអនុម័ត។

### ២.៣. គណៈកម្មការបច្ចេកស័ព្ទមនុស្សសាស្ត្រ និង វិទ្យាសាស្ត្រសង្គម :

គណៈកម្មការបច្ចេកស័ព្ទមនុស្សសាស្ត្រ និង វិទ្យាសាស្ត្រសង្គម មានសមាសភាពចំនួន៨រូប ក្នុងនោះមានប្រធាន១រូប អនុប្រធាន១រូប និង សមាជិក៦រូប។

### ២.៤.គណៈកម្មការបច្ចេកស័ព្ទវិទ្យាសាស្ត្រនយោបាយ និង ការទូត :

គណៈកម្មការបច្ចេកស័ព្ទវិទ្យាសាស្ត្រនយោបាយ និង ការទូត មានសមាសភាពចំនួន៨រូប ក្នុងនោះមានប្រធាន១រូប អនុប្រធាន១រូប និង សមាជិក៦រូប។

### ២.៥.គណៈកម្មការបច្ចេកស័ព្ទភាសាវិទ្យា និង អក្សរសិល្ប៍ :

គណៈកម្មការបច្ចេកស័ព្ទភាសាវិទ្យា និង អក្សរសិល្ប៍ មានសមាសភាពចំនួន៦រូប ក្នុងនោះមានប្រធាន១រូប អនុប្រធាន១រូប និង សមាជិក៤រូប។

### ២.៦.គណៈកម្មការបច្ចេកស័ព្ទវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា :

គណៈកម្មការបច្ចេកស័ព្ទវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា មានសមាសភាពចំនួន៦រូប ក្នុងនោះមានប្រធាន១រូប អនុប្រធាន១រូប និង សមាជិក៤រូប។

### ២.៧.គណៈកម្មការបច្ចេកស័ព្ទវប្បធម៌ និង វិចិត្រសិល្បៈ

គណៈកម្មការបច្ចេកស័ព្ទវប្បធម៌ និង វិចិត្រសិល្បៈ មានសមាសភាពចំនួន៦រូប ក្នុងនោះមានប្រធាន១រូប អនុប្រធាន១រូប និង សមាជិក៤រូប។

### ២.៨.គណៈកម្មការបច្ចេកស័ព្ទជីវសាស្ត្រ វេជ្ជសាស្ត្រ និង កសិកម្ម :

គណៈកម្មការបច្ចេកស័ព្ទជីវសាស្ត្រ វេជ្ជសាស្ត្រ និង កសិកម្ម មានសមាសភាពចំនួន៦រូប ក្នុងនោះមានប្រធាន១រូប អនុប្រធាន១រូប និង សមាជិក៤រូប។

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ១៧.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ

---

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

# ស ម្រេ ច

មាត្រា ១.-

បង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ) ទទួលបន្ទុកកំណត់ឯកភាពនៃការប្រើប្រាស់ភាសាខ្មែរ ដែលមានសមាសភាពដូចតទៅ ÷

| | | |
|---|---|---|
| ១-ឯកឧត្តមបណ្ឌិត **សុខ អាន** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | **ប្រធាន** |
| ២-ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ឡុង សៀម** | អនុប្រធានរាជបណ្ឌិតសភាកម្ពុជា | **អនុប្រធានអចិន្ត្រៃយ៍** |
| ៣-ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ឡាំ ម៉ល់** | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រីទទួលបន្ទុកផ្នែកភាសាវិទ្យា | **អនុប្រធាន** |
| ៤-ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ស៊ុំ ឈុំប៊ុន** | អគ្គលេខាធិការនៃរាជបណ្ឌិតសភាកម្ពុជា | **អគ្គលេខាធិការ** |
| ៥-លោកសាស្ត្រាចារ្យបណ្ឌិត **អ៊ុច ច័ន** | អនុប្រធានវិទ្យាស្ថានភាសាជាតិ | **អគ្គលេខាធិការរង** |
| ៦-លោកអគ្គបណ្ឌិត **ប៊ុត សារឧក្ស** | | **ទីប្រឹក្សា** |
| ៧-ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ស៊ន សំណាង** | ប្រធានរាជបណ្ឌិតសភាកម្ពុជា | **ទីប្រឹក្សា** |
| ៨-ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ឆយ យីហ៊ាង** | អនុប្រធានរាជបណ្ឌិតសភាកម្ពុជា | **ទីប្រឹក្សា** |
| ៩-ព្រះតេជគុណ **យស ហ៊ុត** | ប្រធានស្តីទីសមាគមធម្មទូត និងជាប្រធានមូលនិធិពុទ្ធសាសនាខ្មែរ-វត្តធម្មរង្សី | **សមាជិក** |
| ១០-លោកជំទាវសាស្ត្រាចារ្យបណ្ឌិត **ខ្លូតធីតា** | អនុប្រធានរាជបណ្ឌិតសភាកម្ពុជា | **សមាជិក** |
| ១១-ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **រស់ ចន្ត្រាបុត្រ** | អនុប្រធានរាជបណ្ឌិតសភាកម្ពុជា | **សមាជិក** |
| ១២-ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ខាំ ណេង** | អនុប្រធានរាជបណ្ឌិតសភាកម្ពុជា | **សមាជិក** |
| ១៣-ឯកឧត្តមសាស្ត្រាចារ្យវេជ្ជបណ្ឌិត **សំ សោភាន់** | ប្រធានវិទ្យាស្ថាន ជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម | **សមាជិក** |
| ១៤-ឯកឧត្តមបណ្ឌិតរដ្ឋ **តិច សំណាង** | អគ្គលេខាធិការគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា | **សមាជិក** |
| ១៥-លោកសាស្ត្រាចារ្យបណ្ឌិត **សោម សុមុនី** | អនុប្រធានវិទ្យាស្ថាន មនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម | **សមាជិក** |

| | | |
|---|---|---|
| ១៦-ឯកឧត្តមបណ្ឌិត **ឆយ អូន** | សមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | **សមាជិក** |
| ១៧-ឯកឧត្តម **ឈុន អៀម** | រដ្ឋលេខាធិការនៃក្រសួងធម្មការ និងកិច្ចការសាសនា | **សមាជិក** |
| ១៨-ឯកឧត្តម **ជា ជឿន** | អនុរដ្ឋលេខាធិការនៃក្រសួងធម្មការ និងកិច្ចការសាសនា | **សមាជិក** |
| ១៩-ឯកឧត្តម **ជា គាន** | អគ្គលេខាធិការរងទី១ ក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជា អគ្គលេខាធិការរង គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ | **សមាជិក** |
| ២០-ឯកឧត្តម **សូ មុយឃៀង** | សមាជិកគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ | **សមាជិក** |
| ២១-លោកសាស្ត្រាចារ្យបណ្ឌិត **ស៊ីន ផុស** | សមាជិកគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ | **សមាជិក** |
| ២២-លោកសាស្ត្រាចារ្យបណ្ឌិត **ច័ន្ទ សំណាញ** | ប្រធានដេប៉ាតឺម៉ង់ភាសាវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | **សមាជិក** |
| ២៣-លោកសាស្ត្រាចារ្យ **មៀច ប៉ុណ្ណ** | ទីប្រឹក្សាអមក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ | **សមាជិក** |
| ២៤-លោកសាស្ត្រាចារ្យ **ឡាក់ ឆ្នាំ** | | **សមាជិក** |
| ២៥-លោក **មាស គាំ** | | **សមាជិក** |
| ២៦-លោក **ពៅ ពិសិដ្ឋ** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការ និងព័ត៌មាន នៃគ.ទ.ក | **សមាជិក** |
| ២៧-តំណាងក្រសួងអប់រំ យុវជន និងកីឡា | | **សមាជិក** |
| ២៨-តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | | **សមាជិក** |
| ២៩-តំណាងក្រសួងព័ត៌មាន | | **សមាជិក** |

៣០-តំណាងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ **សមាជិក**

៣១-តំណាងក្រសួង និងស្ថាប័ននានា **សមាជិក**

៣២-តំណាងសមាគមអ្នកនិពន្ធខ្មែរ **សមាជិក**

៣៣-តំណាងពុទ្ធសាសនបណ្ឌិត្យ **សមាជិក**

៣៤-លោកសាស្ត្រាចារ្យ **សន ពៅ** លេខាអចិន្ត្រៃយ៍នៃវិទ្យាស្ថានភាសាជាតិ **លេខាធិការ**

៣៥-លោកសាស្ត្រាចារ្យ **ជួរ គារី** ប្រធានផ្នែកខេមរនីយកម្ម វចនានុក្រម និងបកប្រែ នៃវិទ្យាស្ថានភាសាជាតិ **លេខាធិការ**

៣៦-លោកសាស្ត្រាចារ្យ **ស៊ុំ ឈុំឡេង** លេខាអចិន្ត្រៃយ៍នៃវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម **លេខាធិការ**

មាត្រា ២.-

គណៈកម្មាធិការជាតិភាសាខ្មែរ មានភារកិច្ចកំណត់ឯកភាពនៃភាសាខ្មែរក្នុងការសរសេរ ការអាន និយមន័យ និងការបង្កើតពាក្យ ជាពិសេសកំណត់គោលនយោបាយជាតិនៃភាសា ដើម្បីអភិវឌ្ឍភាសាខ្មែរ ឱ្យចម្រើនឡើងប្រកបដោយនិរន្តរភាព និងរក្សានូវអត្តសញ្ញាណដ៏ថ្លៃថ្នូរនៃជាតិខ្មែរ។

នីតិវិធី និងដំណើរការអនុវត្តភារកិច្ចរបស់គណៈកម្មាធិការជាតិភាសាខ្មែរ ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង។

មាត្រា ៣.-

សមាជិក និងទីប្រឹក្សានៃគណៈកម្មាធិការជាតិភាសាខ្មែរ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

តំណាងក្រសួង ស្ថាប័ននានា ដែលទទួលការចាត់តាំងពីសាមីក្រសួង ស្ថាប័ន នឹងត្រូវអញ្ជើញឱ្យចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ក្នុងករណីចាំបាច់។

គណៈកម្មាធិការនេះ ធ្វើការប្រជុំក្រុមការងារបច្ចេកសព្ទមួយសប្តាហ៍ម្តង និងប្រជុំរួមប្រចាំខែ។ ប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ មានភារកិច្ចកោះប្រជុំដោយកំណត់ប្រធានបទ ទីកន្លែង និងកាលបរិច្ឆេទនៃការប្រជុំតាមការចាំបាច់។ អនុសាសន៍ ឬគោលនយោបាយភាសាខ្មែរ ដែលស្នើឡើងក្នុងអង្គប្រជុំរួមនីមួយៗ នឹងត្រូវដាក់ជូនប្រមុខរាជរដ្ឋាភិបាលសម្រាប់ពិចារណា និងចាត់វិធានការអនុវត្តនៅទូទាំងប្រទេស តាមលទ្ធភាពជាក់ស្តែង។

មាត្រា ៤.-

គណៈកម្មាធិការនេះ មានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមានទីតាំងនៅវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា ជាជំនួយការ។

លេខាធិការដ្ឋាន ជាអង្គភាពបច្ចេកទេសដែលជួយគណៈកម្មាធិការជាតិភាសាខ្មែរ ក្នុងការងារភាសាខ្មែរ ការងាររដ្ឋបាល និងហិរញ្ញកិច្ច ហើយនិងការងារផ្សេងៗទៀតដែលពាក់ព័ន្ធទៅនឹងគណៈកម្មាធិការនេះ ។

សមាសភាព ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាននេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ ។

មាត្រា ៥.-

ថវិកាសម្រាប់ធានាដំណើរការក្នុងលេខាធិការដ្ឋាន និងការប្រជុំនានា ជាថវិកាជាតិតាមគម្រោង ដែលស្នើឡើងដោយគណៈកម្មាធិការជាតិភាសាខ្មែរ តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ។

គណៈកម្មាធិការនេះ អាចទទួលជំនួយឧបត្ថម្ភពីសប្បុរសជន ពីអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ហើយនិងពីប្រភពផ្សេងៗទៀត ។

មាត្រា ៦.-

គណៈកម្មាធិការនេះ អាចបង្កើតក្រុមការងារបច្ចេកស័ព្ទភាសាខ្មែរ និងអនុគណៈកម្មការឯកទេសភាសាខ្មែរផ្សេងៗទៀត តាមសេចក្តីត្រូវការចាំបាច់ ។

មាត្រា ៧.-

គណៈកម្មាធិការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់រាជបណ្ឌិតសភាកម្ពុជា ។

មាត្រា ៨.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសមាសភាពគណៈកម្មាធិការ ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ដូចមាត្រា ៨
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ១៨៩២ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការកែសម្រួលសមាសភាពនៃគណៈកម្មាធិការជាតិភាសាខ្មែរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ មាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៨អនក្រ.បក ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១៖**

ត្រូវបានកែសម្រួលសមាសភាពនៃគណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ) ដែលមានចែងក្នុងមាត្រា១ នៃអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ ដូចតទៅ ÷

១- ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ឡៅ ម៉ល់** ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកផ្នែកភាសាវិទ្យា នៅរាជបណ្ឌិតសភាកម្ពុជា និង អនុប្រធាននៃគណៈកម្មាធិការជាតិភាសាខ្មែរ ជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិភាសាខ្មែរ ជំនួសឯកឧត្តម សាស្ត្រាចារ្យបណ្ឌិត **ឡុង សៀម** ដែលបានទទួលមរណភាព។

២- ឯកឧត្តម **ឈន អៀម** សមាជិកគណៈកម្មាធិការជាតិភាសាខ្មែរ ជាអនុប្រធាននៃគណៈកម្មាធិការជាតិភាសាខ្មែរ ជំនួសឯកឧត្តមសាស្ត្រាចារ្យ បណ្ឌិត **ឡៅ ម៉ល់** ដែលត្រូវទទួលភារកិច្ចថ្មី។

**មាត្រា២៖**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី
គណៈកម្មាធិការជាតិភាសាខ្មែរ

## បទបញ្ជាផ្ទៃក្នុង
## នៃគណៈកម្មាធិការជាតិភាសាខ្មែរ

**ប្រការ ១.-**

បទបញ្ជាផ្ទៃក្នុងនេះ ធ្វើឡើងស្របតាមបញ្ញត្តិនៃអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ។

**ប្រការ ២.-**

គណៈកម្មាធិការជាតិភាសាខ្មែរ សរសេរកាត់ថា គ.ជ.ភ.ខ. មានភារកិច្ចដូចមានចែងក្នុងមាត្រា២នៃអនុក្រឹត្យយោងខាងលើហើយត្រូវទទួលភារកិច្ចសម្រេចពីកម្ចីពាក្យផងដែរ ដោយបញ្ហានេះមានទំនាក់ទំនងជាមួយការបង្កើតពាក្យ។

**ប្រការ ៣.-**

ប្រធាននៃ គ.ជ.ភ.ខ. ជាអធិបតីក្នុងសម័យប្រជុំពេញអង្គ។ អនុប្រធានអចិន្ត្រៃយ៍ អាចជាប្រតិភូទទួលសិទ្ធិពីប្រធាន ដើម្បីដឹកនាំការប្រជុំប្រចាំថ្ងៃ ឬ ធ្វើជាប្រធានប្រជុំផ្សេងៗនៃ គ.ជ.ភ.ខ.។ ក្នុងករណីអនុប្រធានអចិន្ត្រៃយ៍អវត្តមាន អនុប្រធានត្រូវបំពេញភារកិច្ចជំនួស។ ប្រសិនបើអនុប្រធានអវត្តមានផងដែរ ការគ្រប់គ្រងសម័យប្រជុំត្រូវធ្វើឡើងតាមឋានានុក្រមនៃ គ.ជ.ភ.ខ.។

**ប្រការ ៤.-**

សម័យប្រជុំពេញអង្គរបស់ គ.ជ.ភ.ខ. ប្រព្រឹត្តទៅរៀងរាល់ថ្ងៃពុធ ចាប់ពីម៉ោង ១៤:៣០នាទី រហូតដល់ម៉ោង ១៧:៣០នាទី។ ក្នុងករណីចាំបាច់ ការប្រជុំនឹងត្រូវប្រព្រឹត្តទៅពីរដងក្នុងមួយសប្ដាហ៍។ ការប្រជុំនឹងអាចដំណើរការបាន លុះត្រាតែមានកូរ៉ុមលើសពី៥០% នៃចំនួនសមាជិកគ.ជ.ភ.ខ.ទាំងមូល។ បើកូរ៉ុមខាងលើមិនគ្រប់ទេ ប្រធាន អង្គប្រជុំចេញលិខិតរំឭក អញ្ជើញប្រជុំនៅសប្ដាហ៍បន្ទាប់។

**ប្រការ ៥.-**

ការសម្រេចទាំងប៉ុន្មាននៃសម័យប្រជុំនឹងយកជាការបាន លុះណាបានសំឡេងភាគច្រើនដាច់ខាត (ពាក់កណ្ដាលបូកមួយ) នៃសមាជិកចូលរួមបោះឆ្នោត។ ឥស្សរជនដែលមានឈ្មោះក្នុងអនុក្រឹត្យស្ដីពីការបង្កើត គ.ជ.ភ.ខ. តំណាង

អចិន្ត្រៃយ៍នៃក្រសួងឬស្ថាប័ន និង ប្រធានគណៈកម្មការបច្ចេកទេសពាក់ព័ន្ធនានា សុទ្ធតែមានសិទ្ធិបោះឆ្នោតសម្តែងមតិ។ កាលណាមានសំឡេងស្មើគ្នា សំឡេងប្រធានអង្គប្រជុំមានឧត្តមានុភាព។

**ប្រការ ៦.-**

លេខាធិការនៃគ.ជ.ភ.ខ. មានភារកិច្ចធ្វើកំណត់ហេតុនៃការប្រជុំ គ.ជ.ភ.ខ. ដោយអាចសុំមន្ត្រីជំនួយការពីលេខាធិការដ្ឋានអចិន្ត្រៃយ៍។ បន្ទាប់ពីសម័យប្រជុំ លេខាធិការត្រូវយកលទ្ធផលដែល គ.ជ.ភ.ខ. បានអនុម័តទៅសុំហត្ថលេខាឯកភាពពីប្រធានអង្គប្រជុំ ដើម្បីរក្សាទុកនិងចាត់ចែងបន្ត។

**ប្រការ ៧.-**

លេខាធិការដ្ឋានអចិន្ត្រៃយ៍ ស្ថិតនៅក្រោមការទទួលខុសត្រូវរួមរបស់ថ្នាក់ដឹកនាំ ជាអង្គភាពជំនួយការរបស់ គ.ជ.ភ.ខ.ទាំងការងាររដ្ឋបាល ទាំងហិរញ្ញវត្ថុ និង ការងារផ្សេងៗទៀត។

**ប្រការ ៨.-**

លេខាធិការដ្ឋានអចិន្ត្រៃយ៍ ត្រូវស្វែងរកសំណើកែលំអនិងអនុសាសន៍ល្អៗពីគ្រប់មជ្ឈដ្ឋាន ក្រោយពីព្រឹត្តិប័ត្រ ត្រូវបានផ្សព្វផ្សាយរួចហើយ ដើម្បីឱ្យ គ.ជ.ភ.ខ. មានលទ្ធភាពធ្វើសំយោគនិងដាក់លទ្ធផលស្ថាពរជូនប្រធាននៃ គ.ជ.ភ.ខ. ពិនិត្យមុននឹងដាក់ជូនប្រមុខរាជរដ្ឋាភិបាលសម្រេចឱ្យប្រើប្រាស់ទូទាំងប្រទេស។

លទ្ធផលស្ថាពរដែលត្រូវបានប្រកាសឱ្យប្រើទូទាំងប្រទេស ត្រូវចងក្រងជាសទ្ទានុក្រម ដើម្បីងាយស្រួលក្នុងការផ្សព្វផ្សាយ។

**ប្រការ ៩.-**

អនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.ភ.ខ. មានភារកិច្ចចាត់ចែងធ្វើគម្រោងថវិកាជាតិ សម្រាប់ដំណើរការ គ.ជ.ភ.ខ. ស្របតាមមាត្រា៥នៃអនុក្រឹត្យ ស្តីពីការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ។

គណៈកម្មាធិការនេះ ត្រូវស្វះស្វែងរកជំនួយឧបត្ថម្ភ ពីសប្បុរសជន ពីអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ និង ពីប្រភពផ្សេងៗទៀត។

**ប្រការ ១០.-**

គណៈកម្មាធិការជាតិភាសាខ្មែរ ត្រូវបង្កើតគណៈកម្មការបច្ចេកទេស ដែលមានជាអាទិ៍ :

គណៈកម្មការអក្ខរាវិរុទ្ធនិងអំណាន គណៈកម្មការនៃការបង្កើតពាក្យនិងកម្ចីពាក្យ និង គណៈកម្មការបច្ចេកស័ព្ទផ្សេងៗ។ គណៈកម្មការបច្ចេកស័ព្ទអាចបង្កើតអនុគណៈកម្មការឯកទេសតាមសេចក្តីត្រូវការ។

គណៈកម្មការអក្ខរាវិរុទ្ធនិងអំណានត្រូវស្វែងរកឯកភាពក្នុងការសរសេរពាក្យនិងក្នុងការអានពាក្យ។ គណៈកម្មការនៃការបង្កើតពាក្យនិងកម្ចីពាក្យ ត្រូវផ្អែកលើមូលដ្ឋានវេយ្យាករណ៍ជាក់លាក់ ដើម្បីកំណត់គោលការណ៍នៃការបង្កើតពាក្យថ្មី សម្រាប់ឱ្យគណៈកម្មការបច្ចេកស័ព្ទផ្សេងៗអនុវត្តតាម។ ចំពោះពាក្យកម្ចី គណៈកម្មការនេះក៏ត្រូវស្វែងរកនិងកំណត់គោលការណ៍ជាក់លាក់ ផ្អែកលើមូលដ្ឋានវេយ្យាករណ៍ និងលក្ខណៈវិនិច្ឆ័យច្បាស់លាស់ដូចគ្នាដែរ ដែលតម្រូវឱ្យអ្នកប្រើប្រាស់ភាសាអនុវត្តតាម ដើម្បីចៀសវាងភាពអនាធិបតេយ្យក្នុងភាសាខ្មែរ ជាពិសេសក្នុងការប្រើប្រាស់ជាសាធារណៈ តាមសាលារៀន តាមវិទ្យុ តាមទូរទស្សន៍ និង តាមការបោះពុម្ពផ្សាយ។

គណៈកម្មការបច្ចេកស័ព្ទនីមួយៗ ត្រូវមានអ្នកជំនាញមុខវិជ្ជាជាប្រធាន និង អ្នកភាសាវិទ្យាមួយ ឬ ពីរនាក់ជាសមាជិកសម្រាប់ជួយបំភ្លឺបញ្ហាភាសា។

ប្រធានគណៈកម្មការបច្ចេកទេស ជាសមាជិករាយការណ៍សម្រាប់លទ្ធផលនៃគណៈកម្មការរបស់ខ្លួន ក្នុងសម័យប្រជុំនៃ គ.ជ.ភ.ខ.។

បទបញ្ជាផ្ទៃក្នុងនេះត្រូវបាន គ.ជ.ភ.ខ.អនុម័តបញ្ចប់
នៅថ្ងៃពុធ ទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំរបស់ខ្លួន។

រាជធានីភ្នំពេញ ថ្ងៃ 24 ខែ 12 ឆ្នាំ ២០០៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ**

**សុខ អាន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខៈ..១៧១..សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍
# នៃគណៈកម្មាធិការជាតិភាសាខ្មែរ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពី ការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពី ការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និង មាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពី ការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៧ ស្តីពី ការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ
- យោងតាមការចាំបាច់នៃគណៈកម្មាធិការជាតិភាសាខ្មែរ

## ស ម្រេ ច

**ប្រការ១.–**

បង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិភាសាខ្មែរ មានការិយាល័យចំនួន០៣ គឺការិយាល័យរដ្ឋបាល ការិយាល័យហិរញ្ញវត្ថុ និង ការិយាល័យបោះពុម្ពផ្សាយ ។ ការិយាល័យនីមួយៗត្រូវមាន ប្រធាន អនុប្រធាន និងសមាជិក ។

**ប្រការ២.-**

ការិយាល័យរដ្ឋបាល មានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១- លោក **ជួរ គរី** | ប្រធានផ្នែកខេមរនីយកម្ម វចនានុក្រម និង បកប្រែ នៃវិទ្យាស្ថានភាសាជាតិ | **ប្រធាន** |
| ២- លោក **មាឃ បូរ៉ា** | មន្ត្រីវិទ្យាស្ថានភាសាជាតិ | **អនុប្រធាន** |
| ៣- លោក **ណុន សុខា** | មន្ត្រីវិទ្យាស្ថានភាសាជាតិ | **អនុប្រធាន** |
| ៤- លោក **ជួន សោរិទ្ធី** | មន្ត្រីវិទ្យាស្ថានភាសាជាតិ | **សមាជិក** |
| ៥- លោកស្រី **គាវ ណារ៉ា** | មន្ត្រីវិទ្យាស្ថានភាសាជាតិ | **សមាជិក** |

**ប្រការ៣.-**

ការិយាល័យរដ្ឋបាល មានតួនាទី និង ភារកិច្ច ដូចខាងក្រោម ÷

- ធានាប្រសិទ្ធភាព និង សុវត្ថិភាពនៃដំណើរការងារ
- គ្រប់គ្រងលើការធ្វើចរាចរលិខិតគ្រប់ប្រភេទ
- ទទួលបន្ទុកពិធីការ ការរៀបចំការប្រជុំ សិក្ខាសាលា និង ពិធីផ្សេងៗ
- សហការធ្វើកំណត់ហេតុអង្គប្រជុំ
- សហការបូកសរុបរបាយការណ៍ និង ធ្វើផែនការរួមរបស់គណៈកម្មាធិការជាតិភាសាខ្មែរ
- សហការធ្វើសេចក្តីព្រាងលើលិខិតផ្សេងៗ
- ធ្វើរបាយការណ៍ពីលទ្ធផល និង សកម្មភាពការងាររបស់ខ្លួនតាមការកំណត់
- រក្សានិងតម្កល់ទុករាល់ឯកសារផ្សេងៗ
- ធានាលើការងារអនាម័យ
- ទទួលបន្ទុកលើការងារ បុគ្គលិក និង សហការធ្វើការងារនីតិកម្ម និង អនុវត្តភារកិច្ចផ្សេងៗ តាមការចាំបាច់របស់គណៈកម្មាធិការជាតិភាសាខ្មែរ ។

**ប្រការ៤.-**

ការិយាល័យហិរញ្ញវត្ថុ មានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១- លោក **សន ពៅ** | លេខាអចិន្ត្រៃយ៍នៃវិទ្យាស្ថានភាសាជាតិ | **ប្រធាន** |
| ២- លោក **លី សុធីរ័ត្ន** | ប្រធានគណនេយ្យនៃរាជបណ្ឌិតសភាកម្ពុជា | **អនុប្រធាន** |
| ៣- លោក **លាង សុភាព** | អនុប្រធានផ្នែកខេមរនីយកម្ម វចនានុក្រម និង បកប្រែ នៃវិទ្យាស្ថានភាសាជាតិ | **អនុប្រធាន** |
| ៤- លោក **ឃិន យ៉េង** | មន្ត្រីរដ្ឋបាលនៃរាជបណ្ឌិតសភាកម្ពុជា | **សមាជិក** |
| ៥- លោកស្រី **មាង ថាវី** | មន្ត្រីវិទ្យាស្ថានភាសាជាតិ | **សមាជិក** |

**ប្រការ៥.-**

ការិយាល័យហិរញ្ញវត្ថុ មានតួនាទី និង ភារកិច្ចដូចខាងក្រោម ÷

- ធ្វើបញ្ជី និង គម្រោង ចំណូល-ចំណាយ
- ធ្វើបញ្ជីសារពើភណ្ឌ ចលនទ្រព្យ និង អចលនទ្រព្យ

- ទទួលខុសត្រូវ ថែរក្សា បញ្ជីកត់ត្រា គណនេយ្យ និង ការងារបេឡា
- ធ្វើទំនាក់ទំនងលើបញ្ហាថវិកាជាមួយទីស្ដីការគណៈរដ្ឋមន្ត្រី
- ធ្វើរបាយការណ៍ពីលទ្ធផល និង សកម្មភាពការងាររបស់ខ្លួនតាមកាលកំណត់ និង អនុវត្តភារកិច្ចផ្សេងៗទៀត តាមការចាំបាច់របស់គណៈកម្មាធិការជាតិភាសាខ្មែរ ។

**ប្រការ៦.-**

ការិយាល័យបោះពុម្ពផ្សាយ មានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- លោក **ស៊ុំ ឈុំឡុង** | លេខាធិការអចិន្ត្រៃយ៍នៃវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម | **ប្រធាន** |
| ២- លោក **សេ អឿន** | មន្ត្រីវិទ្យាស្ថានភាសាជាតិ | **អនុប្រធាន** |
| ៣- លោក **មី សុខគង់** | មន្ត្រីវិទ្យាស្ថានភាសាជាតិ | **អនុប្រធាន** |
| ៤- លោក **ឡុង សុរិទ្ធ** | មន្ត្រីផ្នែកខុទ្ទកាល័យនៃរាជបណ្ឌិតសភាកម្ពុជា | **សមាជិក** |
| ៥- លោកស្រី **គិម ស៊ីណា** | មន្ត្រីវិទ្យាស្ថានភាសាជាតិ | **សមាជិក** |

**ប្រការ៧.-**

ការិយាល័យបោះពុម្ពផ្សាយ មានតួនាទី និង ភារកិច្ចដូចខាងក្រោម ៖

- ចាត់ចែងថតរូបភាព
- រៀបចំចងក្រងនិងបោះពុម្ពពាក្យ ដែលគណៈកម្មាធិការជាតិភាសាខ្មែរអនុម័ត ដើម្បីធ្វើជា ព្រឹត្តិប័ត្រ សទ្ទានុក្រម ផ្សព្វផ្សាយប្រើប្រាស់ជាសាធារណៈ និង
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការចាំបាច់របស់គណៈកម្មាធិការជាតិភាសាខ្មែរ ។

**ប្រការ៨.-**

គណៈកម្មាធិការជាតិភាសាខ្មែរ និង សមាសភាពដូចមានចែងក្នុង ប្រការ២ ប្រការ៤ និង ប្រការ៦ ត្រូវអនុវត្តសេចក្ដីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ៥ ឆ្នាំ២០០៧

**ឧបនាយករដ្ឋមន្ត្រី**

**សុខ អាន**

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- រាជបណ្ឌិតសភាកម្ពុជា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចប្រការ ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខៈ ១៥៣.ស.សរ

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការបច្ចេកទេស

## នៃគណៈកម្មាធិការជាតិភាសាខ្មែរ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពី ការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពី ការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និង មាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពី ការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ
- យោងតាមការចាំបាច់នៃគណៈកម្មាធិការជាតិភាសាខ្មែរ

## ស ម្រេ ច

**ប្រការ ១.–**

បង្កើតគណៈកម្មការអក្ខរាវិរុទ្ធនិងអំណាន ដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១- ឯកឧត្តម **ឈន អឿម** | រដ្ឋលេខាធិការនៃក្រសួងធម្មការ និង កិច្ចការសាសនា | **ប្រធាន** |
| ២- ឯកឧត្តម សាស្ត្រាចារ្យបណ្ឌិត **អ៊ឹម ច័ន** | ប្រធានវិទ្យាស្ថានភាសាជាតិ | **អនុប្រធាន** |
| ៣- ឯកឧត្តម សាស្ត្រាចារ្យបណ្ឌិត **ស៊ិន សំណាង** | ប្រធានរាជបណ្ឌិតសភាកម្ពុជា | **ទីប្រឹក្សា** |
| ៤- ឯកឧត្តម បណ្ឌិត **ឆយ អ៊ួន** | សមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ | **សមាជិក** |
| ៥- ឯកឧត្តម សាស្ត្រាចារ្យបណ្ឌិត **ឆ សោ** | ទីប្រឹក្សារាជរដ្ឋាភិបាល | **សមាជិក** |
| ៦- ឯកឧត្តម សាស្ត្រាចារ្យបណ្ឌិត **ម៉ៅ សុវណ្ណ** | សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | **សមាជិក** |
| ៧- ឯកឧត្តម **សូ មុយឃៀង** | សមាជិកគណៈកម្មការបណ្ឌិតសភា ទទួលបន្ទុកអនុម័តពាក្យច្បាប់ | **សមាជិក** |
| ៨- លោកសាស្ត្រាចារ្យ **មៀច ម៉ុណ្ណា** | ទីប្រឹក្សាអមក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ | **សមាជិក** |
| ៩- លោកសាស្ត្រាចារ្យ **ថាច់ សែម** | សមាជិកគណៈកម្មការបណ្ឌិតសភា ទទួលបន្ទុកអនុម័តពាក្យច្បាប់ | **សមាជិក** |
| ១០- លោក **ជួន ជីទិន** | ប្រធានផ្នែកភូមិវិទ្យានិងនគរូបនីយកម្ម នៃវិទ្យាស្ថានមនុស្សសាស្ត្រ និង វិទ្យាសាស្ត្រសង្គម | **សមាជិក** |
| ១១- លោក **កែវ លីណែត** | មន្ត្រីនៃវិទ្យាស្ថានភាសាជាតិ | **លេខាធិការ** |

**ប្រការ ២.–**

គណៈកម្មការអក្ខរាវិរុទ្ធនិងអំណាន មានភារកិច្ចប្រមូលពាក្យនិងកំណត់ការអានពាក្យនៅក្នុងភាសាខ្មែរ ដែលមានបញ្ហានាពេលបច្ចុប្បន្ននេះ ក្នុងគោលបំណងស្វែងរកឯកភាពនៃការសរសេរពាក្យនិងការអានពាក្យនៅក្នុងភាសាខ្មែរ ដើម្បីដាក់ជូនគណៈកម្មាធិការជាតិភាសាខ្មែរអនុម័ត។

**ប្រការ ៣.–**

បង្កើតគណៈកម្មការនៃការបង្កើតពាក្យនិងកម្ចីពាក្យ ដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១- ឯកឧត្តម សាស្ត្រាចារ្យបណ្ឌិត **ស៊ុំ ឈុំប៊ុន** | អគ្គលេខាធិការនៃរាជបណ្ឌិតសភាកម្ពុជា | **ប្រធាន** |
| ២- លោកសាស្ត្រាចារ្យបណ្ឌិត **ច័ន្ទ សំណព្វ** | ប្រធានដេប៉ាតឺម៉ង់ភាសាវិទ្យា | |

| | | |
|---|---|---|
| | នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | **អនុប្រធាន** |
| ៣- ឯកឧត្តម សាស្ត្រាចារ្យបណ្ឌិត **រស់ ចន្ទ្រាបុត្រ** | អនុប្រធានរាជបណ្ឌិតសភាកម្ពុជា | **សមាជិក** |
| ៤- លោកជំទាវ សាស្ត្រាចារ្យបណ្ឌិត **ខ្លូត ធីតា** | អនុប្រធានរាជបណ្ឌិតសភាកម្ពុជា | **សមាជិក** |
| ៥- ឯកឧត្តម សាស្ត្រាចារ្យវេជ្ជបណ្ឌិត **សំ សោភាន់** | អនុប្រធានរាជបណ្ឌិតសភាកម្ពុជា | **សមាជិក** |
| ៦- ឯកឧត្តម សាស្ត្រាចារ្យបណ្ឌិត **ជា ណេន** | អនុប្រធានរាជបណ្ឌិតសភាកម្ពុជា | **សមាជិក** |
| ៧- ឯកឧត្តម បណ្ឌិតវដ្ឋ **តិច សំណាង** | អគ្គលេខាធិការគណៈកម្មាធិការ ទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា | **សមាជិក** |
| ៨- ឯកឧត្តម សាស្ត្រាចារ្យបណ្ឌិត **សោម សុមុនី** | ប្រធានវិទ្យាស្ថាន មនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម | **សមាជិក** |
| ៩- លោកសាស្ត្រាចារ្យបណ្ឌិត **សុខ ទូច** | អនុប្រធានវិទ្យាស្ថានទំនាក់ទំនង អន្តរជាតិកម្ពុជា | **សមាជិក** |
| ១០- លោកសាស្ត្រាចារ្យ **ស៊ីន ផុស** | សមាជិកគណៈកម្មការបណ្ឌិតសភា ទទួលបន្ទុកអនុម័តពាក្យច្បាប់ | **សមាជិក** |
| ១១- កញ្ញា **សុខ ឧស្សាហ៍** | មន្ត្រីនៃវិទ្យាស្ថានភាសាជាតិ | **លេខាធិការ** |

**ប្រការ ៤.-**

គណៈកម្មការនៃការបង្កើតពាក្យនិងកម្ម៉ីពាក្យ មានភារកិច្ចកំណត់គោលការណ៍ក្នុងការបង្កើតពាក្យនិងកម្ម៉ី-ពាក្យ ក្នុងគោលបំណងស្វែងរកឯកភាពនៃការបង្កើតពាក្យនិងកម្ម៉ីពាក្យ ដើម្បីដាក់ជូនគណៈកម្មាធិការជាតិភាសាខ្មែរអនុម័ត ។

**ប្រការ ៥.-**

បង្កើតគណៈកម្មការបច្ចេកស័ព្ទ មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១- ឯកឧត្តម សាស្ត្រចារ្យបណ្ឌិត **សោម សុមុនី** | ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម | **ប្រធាន** |
| ២- លោក **មាឃ សារី** | មន្ត្រីផ្នែកវិទ្យាសាស្ត្រអប់រំ | **អនុប្រធាន** |
| ៣- លោក **អ៊ុន យ៉េត** | មន្ត្រីផ្នែកភូមិវិទ្យានិងដែនដីនគរូបនីយកម្ម | **សមាជិក** |
| ៤- លោក **សូត្រ សំណាង** | មន្ត្រីលេខាធិការដ្ឋានអចិន្ត្រៃយ៍ | **សមាជិក** |
| ៥- លោក **សួ ប៊ុណ្ណារ៉ាត់** | មន្ត្រីផ្នែកប្រវត្តិសាស្ត្រនិងនយោបាយ | **សមាជិក** |
| ៦- លោក **ជា មុនីឫទ្ធិ** | មន្ត្រីផ្នែកទស្សនវិជ្ជានិងសង្គមវិជ្ជា | **សមាជិក** |
| ៧- លោក **ហាក់ ម៉ាន់ដារ៉ា** | មន្ត្រីផ្នែកនរវិទ្យា | **សមាជិក** |
| ៨- លោក **ផង់ តិរុណា** | មន្ត្រីនៃវិទ្យាស្ថានភាសាជាតិ ផ្នែកភាសាវិទ្យា | **សមាជិក** |

**ប្រការ ៦.-**

គណៈកម្មការបច្ចេកស័ព្ទមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម មានភារកិច្ចប្រមូលវាក្យស័ព្ទដែលមានប្រើរួចមកហើយ និងបង្កើតពាក្យថ្មីក្នុងមុខវិជ្ជានេះ ដើម្បីស្វែងរកឯកភាពដាក់ជូនគណៈកម្មាធិការជាតិភាសាខ្មែរ អនុម័ត។

**ប្រការ ៧.-**

បង្កើតគណៈកម្មការបច្ចេកស័ព្ទ វិទ្យាសាស្ត្រនយោបាយនិងការទូត ដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១- លោកសាស្ត្រាចារ្យបណ្ឌិត **សុខ ទូច** | អនុប្រធានវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិ | **ប្រធាន** |
| ២- លោកសាស្ត្រាចារ្យបណ្ឌិត **គា គីរីរេណុល** | អនុប្រធានវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិ | **អនុប្រធាន** |
| ៣- លោក **ហង់ ឆារុន** | មន្ត្រីផ្នែកទំនាក់ទំនងសង្គមកិច្ចនិងសុខាភិបាល | **សមាជិក** |
| ៤- លោក **គីក មេង** | មន្ត្រីផ្នែកទំនាក់ទំនងកសិកម្ម បរិស្ថាន និងថាមពលអន្តរជាតិ | **សមាជិក** |
| ៥- លោក **ឈត ម៉ិនថង** | មន្ត្រីផ្នែកទំនាក់ទំនងសង្គមកិច្ចនិងសុខាភិបាល | **សមាជិក** |
| ៦- លោក **សាន លាង** | មន្ត្រីផ្នែកទំនាក់ទំនងសង្គមកិច្ចនិងសុខាភិបាល | **សមាជិក** |
| ៧- កញ្ញា **គីម កែវកល្យាណ** | មន្ត្រីវិទ្យាស្ថានភាសាជាតិ ផ្នែកភាសាវិទ្យា | **សមាជិក** |
| ៨- លោក **ហុង វណ្ណៈ** | មន្ត្រីផ្នែកទំនាក់ទំនងសង្គមកិច្ចនិងសុខាភិបាល | **លេខាធិការ** |

**ប្រការ ៨.-**

គណៈកម្មការបច្ចេកស័ព្ទ វិទ្យាសាស្ត្រនយោបាយនិងការទូត មានភារកិច្ចប្រមូលវាក្យស័ព្ទដែលមានប្រើរួចមកហើយ និងបង្កើតពាក្យថ្មីក្នុងមុខវិជ្ជានេះ ដើម្បីស្វែងរកឯកភាពដាក់ជូនគណៈកម្មាធិការជាតិភាសាខ្មែរ អនុម័ត។

**ប្រការ ៩.-**

បង្កើតគណៈកម្មការបច្ចេកស័ព្ទ ភាសាវិទ្យានិងអក្សរសិល្ប៍ ដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១- ឯកឧត្តម សាស្ត្រាចារ្យបណ្ឌិត **ឡាំ ម៉ល់** | ទីប្រឹក្សាអមទីស្ដីការគណៈរដ្ឋមន្ត្រីទទួលបន្ទុកភាសាវិទ្យា | **ប្រធាន** |
| ២- ឯកឧត្តម សាស្ត្រាចារ្យបណ្ឌិត **អ៊ឹង ច័ន** | ប្រធានវិទ្យាស្ថានភាសាជាតិ | **អនុប្រធាន** |
| ៣- ឯកឧត្តម សាស្ត្រាចារ្យបណ្ឌិត **ស៊ុំ ឈុំប៊ុន** | អគ្គលេខាធិការនៃរាជបណ្ឌិតសភាកម្ពុជា | **សមាជិក** |
| ៤- ឯកឧត្តម សាស្ត្រាចារ្យបណ្ឌិត **ម៉ៅ សុគ្គន** | សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | **សមាជិក** |
| ៥- ឯកឧត្តម សាស្ត្រាចារ្យ **ម៉ុញ សរី** | អនុប្រធានអចិន្ត្រៃយ៍លេខាធិការដ្ឋាននៃគណៈកម្មការបណ្ឌិតសភាទទួលបន្ទុក | |

| | | |
|---|---|---|
| | អនុម័តពាក្យច្បាប់ | **សមាជិក** |
| ៦- លោកសាស្ត្រាចារ្យ **សុខ កុសល** | សាកលវិទ្យាធិការរង<br>នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | **សមាជិក** |

**ប្រការ ១០.-**

គណៈកម្មការបច្ចេកស័ព្ទ ភាសាវិទ្យានិងអក្សរសិល្ប៍ មានភារកិច្ចប្រមូលវាក្យស័ព្ទដែលមានប្រើរួចមកហើយ និងបង្កើតពាក្យថ្មីក្នុងមុខវិជ្ជាទាំងពីរនេះ ដើម្បីស្វែងរកឯកភាពដាក់ជូនគណៈកម្មាធិការជាតិភាសាខ្មែរ អនុម័ត ។

**ប្រការ ១១.-**

បង្កើតគណៈកម្មការបច្ចេកស័ព្ទ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១- ឯកឧត្តម សាស្ត្រាចារ្យបណ្ឌិត **អ៊ាង ចន្ទ្រណ្ណា** | ប្រធានវិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា | **ប្រធាន** |
| ២- លោកស្រី សាស្ត្រាចារ្យបណ្ឌិត **សៀង ហ៊ុយ** | ប្រធានផ្នែកគីមី | **អនុប្រធាន** |
| ៣- ឯកឧត្តម សាស្ត្រាចារ្យ **អ៊ុំ ប៉ុម** | អគ្គលេខាធិការរងទទួលបន្ទុក<br>រដ្ឋបាលនិងហិរញ្ញវត្ថុ | **សមាជិក** |
| ៤- លោក **យឹម អាយុទឡ្ហនៈវិជ្ជា** | មន្ត្រីផ្នែកគណិត | **សមាជិក** |
| ៥- លោក **លឹម សេងឌី** | មន្ត្រីផ្នែកកុំព្យូទ័រ | **សមាជិក** |
| ៦- លោក **អ៊ុក សៅបុល** | មន្ត្រីវិទ្យាស្ថានភាសាជាតិ ផ្នែកភាសាវិទ្យា | **សមាជិក** |

**ប្រការ ១២.-**

គណៈកម្មការបច្ចេកស័ព្ទ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា មានភារកិច្ចប្រមូលវាក្យស័ព្ទ ដែលមានប្រើរួចមកហើយ និងបង្កើតពាក្យថ្មីក្នុងមុខវិជ្ជាទាំងពីរនេះ ដើម្បីស្វែងរកឯកភាពដាក់ជូនគណៈកម្មាធិការជាតិភាសាខ្មែរ អនុម័ត ។

**ប្រការ ១៣.-**

បង្កើតគណៈកម្មការបច្ចេកស័ព្ទ វប្បធម៌និងវិចិត្រសិល្បៈ ដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១- លោកសាស្ត្រាចារ្យបណ្ឌិត **នូ ចាន់សុភី** | លេខាអចិន្ត្រៃយ៍វិទ្យាស្ថាន<br>វប្បធម៌និងវិចិត្រសិល្បៈ | **ប្រធាន** |
| ២- លោក **ផុន កសិកា** | មន្ត្រីវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ | **អនុប្រធាន** |
| ៣-លោកស្រី សាស្ត្រាចារ្យបណ្ឌិត **ឡាំ ទេវី** | ប្រធានផ្នែកបោះពុម្ពផ្សាយ | **សមាជិក** |
| ៤- លោក **លឹម សូក្រាត** | មន្ត្រីវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ | **សមាជិក** |
| ៥- លោក **ហៀង លាងហុង** | មន្ត្រីវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ | **សមាជិក** |
| ៦- លោកស្រី **អ៊ុង ម៉ាល័យ** | មន្ត្រីវិទ្យាស្ថានភាសាជាតិ ផ្នែកភាសាវិទ្យា | **សមាជិក** |

**ប្រការ ១៤.-**

គណៈកម្មការបច្ចេកស័ព្ទ វប្បធម៌និងវិចិត្រសិល្បៈ មានភារកិច្ចប្រមូលវាក្យស័ព្ទ ដែលមានប្រើរួចមកហើយ និង បង្កើតពាក្យថ្មីក្នុងមុខវិជ្ជាទាំងពីរនេះ ដើម្បីស្វែងរកឯកភាពដាក់ជូនគណៈកម្មាធិការជាតិភាសាខ្មែរ អនុម័ត ។

**ប្រការ ១៥.-**

បង្កើតគណៈកម្មការបច្ចេកស័ព្ទ ជីវសាស្ត្រ វេជ្ជសាស្ត្រ និង កសិកម្ម ដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១- ឯកឧត្តម សាស្ត្រាចារ្យឱសថបណ្ឌិត **ម៉ែន ជួនពីច** អនុប្រធានវិទ្យាស្ថាន ជីវសាស្ត្រ | វេជ្ជសាស្ត្រនិងកសិកម្ម | **ប្រធាន** |
| ២- លោកសាស្ត្រាចារ្យវេជ្ជបណ្ឌិត **នុត សម្បត្តិ** | ប្រធានផ្នែកវេជ្ជសាស្ត្រ | **អនុប្រធាន** |
| ៣- ឯកឧត្តម សាស្ត្រាចារ្យបណ្ឌិត **សាមុ អុហ្សូរាណ្ហ** | អគ្គលេខាធិការរងទទួលបន្ទុក ផ្នែកបណ្តុះបណ្តាលនិងស្រាវជ្រាវ | **សមាជិក** |
| ៤- លោកសាស្ត្រាចារ្យបណ្ឌិត **ស៊ុន សុត** | ប្រធានផ្នែកកសិកម្ម | **សមាជិក** |
| ៥- លោក **រស់ ផាន្នី** | មន្ត្រីផ្នែកជីវសាស្ត្រ | **សមាជិក** |
| ៦- លោក **ខន្ធ មេខ** | មន្ត្រីវិទ្យាស្ថានភាសាជាតិ ផ្នែកភាសាវិទ្យា | **សមាជិក** |

**ប្រការ ១៦.-**

គណៈកម្មការបច្ចេកស័ព្ទ ជីវសាស្ត្រ វេជ្ជសាស្ត្រ និង កសិកម្ម មានភារកិច្ចប្រមូលវាក្យស័ព្ទដែលមានប្រើរួចមកហើយ និងបង្កើតពាក្យថ្មីក្នុងមុខវិជ្ជាទាំងនេះ ដើម្បីស្វែងរកឯកភាពដាក់ជូនគណៈកម្មាធិការជាតិភាសាខ្មែរ អនុម័ត ។

**ប្រការ ១៧.-**

គណៈកម្មាធិការជាតិភាសាខ្មែរ និង សមាសភាពដូចមានចែងក្នុង ប្រការ១ ប្រការ៣ ប្រការ៥ ប្រការ៧ ប្រការ៩ ប្រការ១១ ប្រការ១៣ និង ប្រការ១៥ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី 21 ខែ 12 ឆ្នាំ២០០៧

**ឧបនាយករដ្ឋមន្ត្រី**

**សុខ អាន**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- រាជបណ្ឌិតសភាកម្ពុជា
- ដូចប្រការ១៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី
លេខ:..១៦៤ ស.សរ

# សេចក្ដីសម្រេច
# ស្ដីពី
# ការបង្កើតគណៈកម្មការអាដហុក
# ដើម្បីពិនិត្យនិងផ្ដល់យោបល់លើសៀវភៅ វេយ្យាករណ៍ភាសាខ្មែរ
# របស់លោកសាស្ត្រាចារ្យបណ្ឌិត ឃីន សុខ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីព ការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពី ការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្ដីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និង មាត្រា២០ នៃព្រះរាជក្រឹត្យលេខនស/រកត/១២៩៩/២២០ ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ១៩៩៩ ស្ដីពី ការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៨អនក្រ.បក ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ
- យោងតាមការចាំបាច់

## ស ម្រេ ច

**ប្រការ១.–**

បង្កើតគណៈកម្មការអាជ្ញាហុក ដើម្បីពិនិត្យនិងផ្តល់យោបល់លើសៀវភៅវេយ្យាករណ៍ភាសាខ្មែរ របស់លោកសាស្ត្រាចារ្យបណ្ឌិត ឃីន សុខ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១- ឯកឧត្តម **សូ មុយឃៀង** | សមាជិកគណៈកម្មការបណ្ឌិតសភា ទទួលបន្ទុកអនុម័តពាក្យច្បាប់ | **ប្រធាន** |
| ២- ឯកឧត្តម សាស្ត្រាចារ្យបណ្ឌិត **ស៊ុំ ឈុំប៊ុន** | អគ្គលេខាធិការនៃរាជបណ្ឌិតសភាកម្ពុជា | **អនុប្រធាន** |
| ៣- ឯកឧត្តម សាស្ត្រាចារ្យបណ្ឌិត **ស៊ីន សំណាង** | ប្រធានរាជបណ្ឌិតសភាកម្ពុជា | **ទីប្រឹក្សា** |
| ៤- ឯកឧត្តម សាស្ត្រាចារ្យបណ្ឌិត **អ៊ឹម ច័ន** | ប្រធានវិទ្យាស្ថានភាសាជាតិ | **សមាជិក** |
| ៥- ឯកឧត្តម សាស្ត្រាចារ្យបណ្ឌិត **សោម សុមុនី** | ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រ និង វិទ្យាសាស្ត្រសង្គម | **សមាជិក** |
| ៦- ឯកឧត្តម សាស្ត្រាចារ្យបណ្ឌិត **ម៉ៅ សុភ្ជុន** | សាកលវិទ្យាធិការរងនៃ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | **សមាជិក** |
| ៧- លោកសាស្ត្រាចារ្យបណ្ឌិត **ច័ន្ទ សំណព្វ** | ប្រធានដេប៉ាតឺម៉ង់ភាសាវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | **សមាជិក** |
| ៨- លោកសាស្ត្រាចារ្យបណ្ឌិត **នៅ ស៊ុន** | មន្ត្រីនៃនាយកដ្ឋានស្រាវជ្រាវគរុកោសល្យ | **សមាជិក** |
| ៩- លោកសាស្ត្រាចារ្យបណ្ឌិត **ហ៊ាន សុខុម** | ដេប៉ាតឺម៉ង់អក្សរសាស្ត្រខ្មែរ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | **សមាជិក** |
| ១០- លោកសាស្ត្រាចារ្យ **ស៊ីង ផុស** | សមាជិកគណៈកម្មការបណ្ឌិតសភា | |
| ១១- លោកសាស្ត្រាចារ្យ **យី ធន់** | នាយករងអង្គការសន្តិស្ស័គ្រចិត្តកម្ពុជា | **សមាជិក** |
| ១២- លោក **មាឃ បូរ៉ា** | មន្ត្រីស្រាវជ្រាវនៃវិទ្យាស្ថានភាសាជាតិ | **លេខាធិការ** |

**ប្រការ២.–**

គណៈកម្មការអាជ្ញាហុក មានភារកិច្ចពិនិត្យ និង ផ្តល់យោបល់លើលក្ខណៈសម្បត្តិនិងរង្វង់នៃការប្រើប្រាស់សៀវភៅវេយ្យាករណ៍ភាសាខ្មែរ របស់លោកសាស្ត្រាចារ្យបណ្ឌិត **ឃីន សុខ**។

**ប្រការ៣.–**

គណៈកម្មាធិការជាតិភាសាខ្មែរនិងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ១២ ឆ្នាំ២០០៧

**ឧបនាយករដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- ក្រសួង អប់រំ យុវជន និង កីឡា
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- រាជបណ្ឌិតសភាកម្ពុជា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
គណៈកម្មាធិការជាតិភាសាខ្មែរ
លេខាធិការដ្ឋានអចិន្ត្រៃយ៍ : វិទ្យាស្ថានភាសាជាតិ
នៃរាជបណ្ឌិតសភាកម្ពុជា

Comité National de la Langue Khmère
Secrétariat permanent : Institut de la Langue
Nationale de l'Académie Royale du Cambodge

ទូរស័ព្ទ : ០៩២ ៨៩២ ៣៤៣ , ០១៦ ៩៤៧ ៤២១ , ទូរសារ : ០២៣ ៩៨៣ ៨៧១ , E-mail: prummoal@yahoo.com

# កម្មវិធីសិក្ខាសិលា

## ស្តីពី

## "រៀបចំដំណើរការនៃគណៈកម្មាធិការជាតិភាសាខ្មែរ"

## ថ្ងៃព្រហស្បតិ៍ ទី១០ ខែឧសភា ឆ្នាំ២០០៧

**ពេលព្រឹក :**

- ម៉ោង៨:៣០- ៩:០០ : ចុះឈ្មោះសមាជិកចូលរួម
- ម៉ោង៩:០០ : គោរពភ្លេងជាតិ
- ម៉ោង៩:០០-៩:១៥ : សុន្ទរកថាបើកអង្គសិក្ខាសាលា ថ្លែងដោយឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ស៊ន សំណាង** ប្រធានរាជបណ្ឌិតសភាកម្ពុជា និង ជាទីប្រឹក្សាគណៈកម្មាធិការជាតិភាសាខ្មែរ

**វគ្គទី១ :**

ពិភាក្សាផ្តល់យោបល់លើប្រធានបទ "***ប្រវត្តិ និង ការវិវត្តនៃភាសាខ្មែរ***"

អ្នកសម្របសម្រួល :

-ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **រស់ ចន្ទ្រាបុត្រ** អនុប្រធានរាជបណ្ឌិតសភាកម្ពុជា និង ជាសមាជិកគណៈកម្មាធិការជាតិភាសាខ្មែរ

-លោកជំទាវសាស្ត្រាចារ្យបណ្ឌិត **ខ្លូត ធីតា** អនុប្រធានរាជបណ្ឌិតសភាកម្ពុជា និង ជាសមាជិកគណៈកម្មាធិការជាតិភាសាខ្មែរ

- ម៉ោង៩:១៥-៩:៣០ : ទស្សនៈស្តីពី "**ប្រវត្តិ និង ការវិវត្តទូទៅនៃភាសាខ្មែរ**"

ដោយឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ព្រុំ ម៉ល់** ទីប្រឹក្សាអមទីស្ដីការគណៈរដ្ឋមន្ត្រីទទួលបន្ទុកផ្នែកភាសាវិទ្យា និង ជាអនុប្រធានគណៈ-កម្មាធិការជាតិភាសាខ្មែរ

- ម៉ោង៩:៣០-៩:៤៥ :ទស្សនៈស្ដីពី "**ប្រវត្តិ និង ការវិវត្តនៃភាសាខ្មែរ តាមរយៈខេមរយានកម្ម**"

  ដោយឯកឧត្តម **សូ មុយឃៀង** សមាជិកគណៈកម្មការបណ្ឌិតសភាអនុម័តពាក្យច្បាប់ និង ជាសមាជិកគណៈកម្មាធិការជាតិភាសាខ្មែរ

- ម៉ោង៩:៤៥-១០:៤៥ : ពិភាក្សា

- ម៉ោង១០:៤៥-១១:00 :សម្រាក

<u>ខណ្ឌទី២</u> :

<u>ពិភាក្សាផ្ដល់យោបល់លើប្រធានបទ</u> "***ដំណើរការនៃគណៈកម្មាធិការជាតិភាសាខ្មែរ : ទំនាក់ទំនងរវាងសកម្មភាពស្រាវជ្រាវនៃរាជបណ្ឌិតសភាកម្ពុជា និង សកម្មភាពស្រាវជ្រាវនៃគណៈកម្មាធិការជាតិភាសាខ្មែរ ដែលមានលេខាធិការដ្ឋានអចិន្ត្រៃនៅវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា***"

<u>អ្នកសម្របសម្រួល</u> :

-ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ខាំ ឈេខ** អនុប្រធានរាជបណ្ឌិតសភាកម្ពុជា និង ជាសមាជិកគណៈកម្មាធិការជាតិភាសាខ្មែរ

-ឯកឧត្តមសាស្ត្រាចារ្យវេជ្ជបណ្ឌិត **សំ សោភាន់** ប្រធានវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និង កសិកម្ម និង ជាសមាជិកគណៈកម្មាធិការជាតិភាសាខ្មែរ

- ម៉ោង១១:00-១១:១៥ : ទស្សនៈលើប្រធានបទខាងលើរបស់លោកសាស្ត្រាចារ្យបណ្ឌិត **អ៊ុំ ច័ន** អនុប្រធានវិទ្យាស្ថានភាសាជាតិ និង ជាអគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិភាសាខ្មែរ

- ម៉ោង១១:១៥-១១:៣០ : ទស្សនៈលើប្រធានបទខាងលើរបស់លោកសាស្ត្រាចារ្យបណ្ឌិត **ច័ន្ទ សំណព្វ** ប្រធានដេប៉ាតឺម៉ង់ភាសាវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និង ជាសមាជិកគណៈកម្មាធិការជាតិភាសាខ្មែរ

- ម៉ោង១១:៣០-១២:៣០ : ពិភាក្សា

- ម៉ោង១២:៣០-១៤:00 : សម្រាកពិសាអាហារថ្ងៃត្រង់

ពេលរសៀល ៖

ខគ្គទី៣ ៖

ពិភាក្សាផ្តល់យោបល់លើប្រធានបទ ***"ដំណើរការនៃគណៈកម្មាធិការជាតិភាសាខ្មែរ ៖ លំដាប់អាទិភាព នៃដំណោះស្រាយបញ្ហា និង ការបង្កើតអនុគណៈកម្មការបច្ចេកស័ព្ទ"***

អ្នកសម្របសម្រួល ៖

-ឯកឧត្តមបណ្ឌិតរដ្ឋ **គិច សំណាង** អគ្គលេខាធិការគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា និង ជាសមាជិកគណៈកម្មាធិការជាតិភាសាខ្មែរ

-លោកសាស្ត្រាចារ្យវេជ្ជបណ្ឌិត **ប៉ែន ប៊ុនពីឌ** អនុប្រធានវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និង កសិកម្ម

- ម៉ោង១៤:០០-១៤:១៥ ៖ ទស្សនៈលើប្រធានបទខាងលើរបស់ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **រស់ ចន្ត្រាបុត្រ** អនុប្រធានរាជបណ្ឌិតសភាកម្ពុជា និង ជាសមាជិកនៃគណៈកម្មាធិការជាតិភាសាខ្មែរ

- ម៉ោង១១:១៥-១១:៣០ ៖ ទស្សនៈលើប្រធានបទខាងលើរបស់ឯកឧត្តម **ឈន អៀម** រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា និង សមាជិកនៃគណៈកម្មាធិការជាតិភាសាខ្មែរ

- ម៉ោង១៤:៣០-១៦:០០ ៖ ពិភាក្សា

- ម៉ោង១៦:០០-១៦:១៥ ៖ សម្រាក

-ម៉ោង១៦:១៥-១៧:០០ ៖

-ការបូកសរុបលទ្ធផលនៃអង្គសិក្ខាសាលា

ដោយឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ស៊ុំ ឈុំប៊ុន** អគ្គលេខាធិការនៃរាជបណ្ឌិតសភាកម្ពុជា និង ជាអគ្គលេខាធិការនៃគណៈកម្មាធិការជាតិភាសាខ្មែរ

-សុន្ទរកថាបិទអង្គសិក្ខាសាលា

ថ្លែងដោយឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ព្រុំ ម៉ល់** ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រីទទួលបន្ទុកផ្នែកភាសាវិទ្យា និង ជាអនុប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ

-គោរពភ្លេងជាតិបិទកម្មវិធី

# <u>សុន្ទរកថា</u>

## របស់ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ស៊ន សំណាង
## ប្រធានរាជបណ្ឌិតសភាកម្ពុជា និងជាទីប្រឹក្សាគណៈកម្មាធិការជាតិភាសាខ្មែរ
## ក្នុងពិធីបើកសិក្ខាសាលាស្ដីពី "ការរៀបចំដំណើរការនៃគណៈកម្មាធិការជាតិភាសាខ្មែរ"
## ថ្ងៃព្រហស្បតិ៍ ទី១០ ខែឧសភា ឆ្នាំ២០០៧

- សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ
- សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាភ្ញៀវកិត្តិយស
- សូមគោរព ឯកឧត្តម លោក លោកស្រី ជាទីប្រឹក្សា អនុប្រធាន អគ្គលេខាធិការ អគ្គលេខាធិការរង សមាជិក និងលេខាធិការនៃគណៈកម្មាធិការជាតិភាសាខ្មែរ
- សូមគោរព លោក លោកស្រី ជាប្រិយមិត្តទាំងអស់

ថ្ងៃនេះ ខ្ញុំព្រះករុណាខ្ញុំមានកិត្តិយស និងសេចក្ដីរីករាយជាអនេក ដោយបានចូលរួមក្នុងពិធីបើកសិក្ខាសាលាស្ដីពី *"ការរៀបចំដំណើរការនៃគណៈកម្មាធិការជាតិភាសាខ្មែរ"* ដែលមានលេខាធិការដ្ឋានអចិន្ត្រៃយ៍តាំងនៅ វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា។

ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះព្រះតេជគុណ ឯកឧត្តម លោកជំទាវ ជាភ្ញៀវកិត្តិយស និងជាវាគ្មិន ព្រមទាំងចំពោះសាស្ត្រាចារ្យ បណ្ឌិត លោក លោកស្រីទាំងអស់ ដែលបាននិមន្ត និងអញ្ជើញមកចូលរួមក្នុងពិធីបើកសិក្ខាសាលា នាពេលនេះ។

*ព្រះតេជគុណ ឯកឧត្តម លោកជំទាវ លោក លោកស្រី !*

គណៈកម្មាធិការជាតិភាសាខ្មែរ ទើបត្រូវបានបង្កើតឡើងនៅថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៧នេះ ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា។ នេះជាការឆ្លុះបញ្ចាំងឱ្យឃើញនូវការយកចិត្តទុកដាក់របស់សម្ដេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងវិស័យភាសាជាតិ និងការយកចិត្តទុកដាក់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ដែលជាប្រធាននៃគណៈកម្មាធិការនេះ។

ខ្ញុំព្រះករុណាខ្ញុំសូមអនុញ្ញាតរំលឹកជូនថា មហាជនខ្មែរបានទន្ទឹងរង់ចាំគណៈកម្មាធិការនេះជាយូរមកហើយ ជាពិសេស តាំងពីឆ្នាំ២០០០មក ក្រោយពេលដែលវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជាបានធ្វើ សន្និសីទជាតិស្ដីពី *"ការសិក្សាស្រាវជ្រាវ ឯកភាព និងអភិវឌ្ឍន៍ភាសាខ្មែរ"* លើកទី១ នាថ្ងៃទី៧-៩ ខែកញ្ញា។ សន្និសីទជាតិលើកទី១ មានអនុសាសន៍ចំនួន២២ចំណុច ក្នុងនោះ៣ចំណុចសំខាន់ដំបូងគឺ :

១-គប្បីរក្សាទុកព្យញ្ជនៈខ្មែរទាំង៣៣តួ ជាពិសេស អក្សរឡតួ ក្នុងវគ្គ "ដ" ស្រៈពេញតួ និងវណ្ណយុត្តិទាំងអស់

២-គប្បីបង្កើតក្បួនវេយ្យាករណ៍ត្រឹមត្រូវមួយ

៣-គប្បីគោរពពាក្យ រក្សាពាក្យ ដែលមាននៅក្នុងវចនានុក្រមខ្មែររបស់ សម្ដេចព្រះសង្ឃរាជ ជួន ណាត ។

បន្ទាប់មក សន្និសីទជាតិស្ដីពី *"ការសិក្សាស្រាវជ្រាវ ឯកភាព និងអភិវឌ្ឍន៍ភាសាខ្មែរ"* លើកទី២ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៥ មានអនុសាសន៍២២ ចំណុចដែរ ហើយ៤ចំណុចដែលសំខាន់នោះគឺ :

១-សូមឱ្យមានគណៈកម្មាធិការភាសាជាតិមួយ ក្រោមការគ្រប់គ្រងរបស់វិទ្យាស្ថានភាសាជាតិ ដែលមានសមាសភាពមកពីគ្រប់មជ្ឈដ្ឋាន

២-សូមបញ្ចូលពាក្យខ្មែរ ដែលមាននៅក្នុងវចនានុក្រមទៅក្នុងប្រព័ន្ធ Software នៃកុំព្យូទ័រ

៣-សូមប្រមូលចងក្រងពាក្យបច្ចេកទេសថ្មីៗ តាមមុខជំនាញ ដើម្បីងាយស្រួលក្នុងការប្រើប្រាស់នាពេលបច្ចុប្បន្ន

៤-គាំទ្រឱ្យមានការបោះពុម្ពវចនានុក្រមថ្មី ដោយយោងតាមវចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត ដដែល គ្រាន់តែបន្ថែមពាក្យដែលទើបស្រាវជ្រាវរកឃើញថ្មី ។

បន្ទាប់មកទៀត នៅក្នុងសន្និសីទជាតិលើកទី៣ ស្ដីពី *"ការសិក្សាស្រាវជ្រាវ អភិរក្ស និងអភិវឌ្ឍន៍ភាសាខ្មែរលើវិស័យវចនស័ព្ទវិទ្យា និងវចនានុក្រមវិទ្យា"* ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៦នោះ មានអនុ-សាសន៍ចំនួន៧ ហើយ៥ចំណុចសំខាន់ដំបូង មានដូចខាងក្រោមនេះ :

១-សូមបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរឱ្យបានឆាប់

២-សូមឱ្យវិទ្យាស្ថានភាសាជាតិ ប្រមូលចងក្រងបច្ចេកស័ព្ទគ្រប់មុខជំនាញ ដែលប្រើនៅតាមស្ថាប័ន និងនៅតាមគ្រឹះស្ថានឧត្តមសិក្សានានា

៣-សូមបញ្ចូលភាសាបាលី សំស្ក្រឹត និងសិលាចារឹកវិទ្យា ទៅក្នុងកម្មវិធីសិក្សានៃមហាវិទ្យាល័យដែលពាក់ព័ន្ធ

៤-សូមបញ្ចូលពាក្យខ្មែរ ដែលមាននៅក្នុងវចនានុក្រម ទៅក្នុងប្រព័ន្ធ Software

៥-សូមជំរុញការអភិរក្ស និងអភិវឌ្ឍន៍ វចនស័ព្ទវិទ្យា ។

ដោយមានការចូលរួមយ៉ាងសកម្ម ពីឯកឧត្ដមទេសរដ្ឋមន្ត្រី **គាត សេខឃួរ** ដែលបានអញ្ជើញមកជាអ្នកតំណាងរបស់ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី **សុខ អាន** ក្នុងឱកាសបិទសន្និសីទលើកទី៣នោះ គណៈកម្មាធិការជាតិភាសាខ្មែរ អាចបង្កើតឡើងតាមកាលបរិច្ឆេទ ដូចបានជម្រាបជូនខាងលើ ។

*ព្រះតេជគុណ ឯកឧត្ដម លោកជំទាវ លោក លោកស្រី !*

ឥឡូវនេះ យើងបានទទួលនូវអ្វីដែលយើងចង់បានតាំងពីឆ្នាំ២០០០នោះហើយ ។ ភារកិច្ចដែលយើងបានទទួលពីរាជរដ្ឋាភិបាល នៅក្នុងក្របខ័ណ្ឌនៃគណៈកម្មាធិការនេះ មានចែងច្បាស់នៅក្នុងមាត្រា២ នៃអនុក្រឹត្យដែលមានខ្លឹមសារថា : "គណៈកម្មាធិការជាតិភាសាខ្មែរ មានភារកិច្ចកំណត់ឯកភាពនៃភាសាខ្មែរក្នុងការសរសេរ ការអាន និយមន័យ

និងការបង្កើតពាក្យ ជាពិសេសកំណត់គោលនយោបាយជាតិនៃភាសា ដើម្បីអភិវឌ្ឍភាសាខ្មែរឱ្យចម្រើនឡើងប្រកបដោយនិរន្តរភាព និងរក្សានូវអត្តសញ្ញាណដ៏ថ្លៃថ្នូរនៃជាតិខ្មែរ។ នីតិវិធី និងដំណើរការអនុវត្តភារកិច្ចរបស់គណៈកម្មាធិការជាតិភាសាខ្មែរ ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង"។

បន្ទាប់មក នៅក្នុងមាត្រា៣ មានការបញ្ជាក់ថា : "អនុសាសន៍ ឬគោលនយោបាយភាសាខ្មែរ ដែលស្នើឡើងក្នុងអង្គប្រជុំនីមួយៗ នឹងត្រូវដាក់ជូនប្រមុខរាជរដ្ឋាភិបាលសម្រាប់ពិចារណា និងចាត់វិធានការអនុវត្តនៅទូទាំងប្រទេសតាមលទ្ធភាពជាក់ស្តែង"។

ចំណុចសំខាន់មួយទៀតមាននៅក្នុងមាត្រា៦ ដែលចែងថា :"គណៈកម្មាធិការនេះ អាចបង្កើតក្រុមការងារបច្ចេកស័ព្ទភាសាខ្មែរ និងអនុគណៈកម្មការឯកទេសភាសាខ្មែរផ្សេងៗទៀត តាមសេចក្តីត្រូវការចាំបាច់"។

*ព្រះតេជគុណ ឯកឧត្តម លោកជំទាវ លោក លោកស្រី !*

ចំណុចសំខាន់ទាំងប៉ុន្មានខាងលើ ដែលមានចែងនៅក្នុងមាត្រា២ ( កំណត់ឯកភាពនៃភាសាខ្មែរ ក្នុងការសរសេរ ការអាន និយមន័យ និងការបង្កើតពាក្យ ជាពិសេសកំណត់គោលនយោបាយជាតិនៃភាសា) មាត្រា៣ (អនុសាសន៍ ឬគោលនយោបាយភាសាខ្មែរ អាចយកទៅអនុវត្តនៅទូទាំងប្រទេស) និងមាត្រា៦ (អាចបង្កើតក្រុមការងារបច្ចេកស័ព្ទភាសាខ្មែរ និងអនុគណៈកម្មការឯកទេសភាសាខ្មែរផ្សេងៗទៀត) នោះ បង្ហាញអំពីភារកិច្ច ទំហំកិច្ចការ និងការទទួលខុសត្រូវយ៉ាងធំ នៃគណៈកម្មាធិការនេះ ដែលតម្រូវឱ្យមានការខិតខំរួមគ្នា នៅក្នុងគណៈកម្មាធិការទាំងមូល ក្នុងការរៀបចំធនធានមនុស្ស និងការស្វែងរកធនធានហិរញ្ញវត្ថុ សម្រាប់ជំរុញដំណើរការឱ្យបានជោគជ័យ។

ខ្ញុំព្រះករុណាខ្ញុំ មានសេចក្តីសង្ឃឹមថា សិក្ខាសាលានៅថ្ងៃនេះ នឹងពិចារណាលើចំណុចសំខាន់ខាងលើ និងចំណុចផ្សេងៗទៀតដែលមានចែងនៅក្នុងអនុក្រឹត្យ ដោយផ្អែកលើមូលដ្ឋានប្រាកដនិយម ព្រមទាំងលើកនូវមតិ និងសំណូមពរដែលមានលក្ខណៈប្រតិបត្តិ សម្រាប់ដាក់ជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** ដែលជាប្រធាននៃគណៈកម្មាធិការនៅក្នុងការប្រជុំនាពេលខាងមុខ។

នៅទីបញ្ចប់នេះ ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពរចំពោះព្រះថេរានុត្ថេរគ្រប់ព្រះអង្គ និងសូមជូនពរចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ជាភ្ញៀវកិត្តិយស ជាវាគ្មិន និងជាអ្នកចូលរួមទាំងអស់ សូមបានទទួលជោគជ័យក្នុងសិក្ខាសាលានេះ និងបានប្រកបដោយពុទ្ធពរទាំង៥ប្រការ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំព្រះករុណាខ្ញុំ សូមប្រកាសបើកសិក្ខាសាលាស្តីពី "ការរៀបចំដំណើរការនៃគណៈកម្មាធិការជាតិភាសាខ្មែរ" ចាប់ពីពេលនេះតទៅ។

សូមអរព្រះគុណ និងសូមអរគុណ!

**សុន្ទរកថា**

**របស់ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ព្រុំ ម៉ល់**

**ក្នុងឱកាសបិទសិក្ខាសាលា**

**ស្ដីពី**

# "ការរៀបចំដំណើរការនៃគណៈកម្មាធិការជាតិភាសាខ្មែរ"

**ដែលប្រព្រឹត្តទៅនៅរាជបណ្ឌិតសភាកម្ពុជា**

**នាថ្ងៃព្រហស្បតិ៍ ទី១០ ខែឧសភា ឆ្នាំ២០០៧**

**- ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គ !**

**-សូមគោរពឯកឧត្តម លោកជំទាវ លោកបណ្ឌិត លោកសាស្ត្រាចារ្យ លោក លោកស្រី អស់លោកជាភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ ជាទីមេត្រី !**

ខ្ញុំព្រះករុណា ខ្ញុំមានកិត្តិយស និង សោមនស្សរីករាយបំផុត ដោយបានចូលរួមជាអធិបតីភាពនៅក្នុងពិធីបិទអង្គសិក្ខាសាលា ស្ដីពី "ការរៀបចំដំណើរការនៃគណៈកម្មាធិការជាតិភាសាខ្មែរ" ដែលបានប្រារព្ធនៅរាជបណ្ឌិតសភាកម្ពុជានាថ្ងៃនេះ។

ក្នុងនាមខ្ញុំព្រះករុណាខ្ញុំ ជំនួសមុខឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** ប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងនូវសេចក្ដីកោតសរសើរដ៏ស្មោះស្ម័គ្រ ចំពោះសិក្ខាសាលាទាំងមូលនាថ្ងៃនេះ ដែលមានលោកវាគ្មិនជាន់ខ្ពស់របស់ជាតិ ជាពិសេស ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាអ្នកជំនាញ និងជាអ្នកយកចិត្តទុកដាក់លើវិស័យភាសា និង អក្សរសាស្ត្រជាតិ ខិតខំបញ្ចេញមតិយោបល់ ពិភាក្សាវែកញែក និង បង្ហាញបទពិសោធន៍អស់រយៈពេលពេលមួយថ្ងៃនេះ ដើម្បីស្វែងរកគន្លឹះ និង យន្តការ ដែលជាមធ្យោបាយដ៏ល្អមួយឱ្យគណៈកម្មាធិការជាតិភាសាខ្មែរបានជួបប្រជុំគ្នា នៅថ្ងៃខាងមុខ ដើម្បីអនុម័តនូវវិធានការផ្សេងៗដែលជាលទ្ធផលនៃសិក្ខាសាលាថ្ងៃនេះ។

**អង្គសិក្ខាសាលាជាទីមេត្រី!**

អស់រយៈពេលជាង ៣០ឆ្នាំមកហើយ យើងគ្មានគណៈកម្មាធិការជាតិភាសាខ្មែរបែបនេះ កន្លងមក នៅឆ្នាំ ២០០០, ២០០៥, ២០០៦ វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា រៀបចំសន្និសីទជាតិ ស្ដីពីការស្រាវជ្រាវ និងអភិវឌ្ឍន៍ភាសាខ្មែរក្នុងគោលបំណងស្វែងរកគោលឯកភាពគ្នាមួយនៅក្នុងការសិក្សាស្រាវជ្រាវអភិវឌ្ឍន៍ និង ការប្រើប្រាស់ភាសាខ្មែរ។ លទ្ធផលនៃអង្គសិក្ខាសាលានាពេលនោះ យើងទទួលបាននូវអនុសាសន៍ជាច្រើនចំណុច ដើម្បីជាគោលការណ៍

សម្រាប់ការស្រាវជ្រាវ និង អនុវត្តនីលើវិស័យភាសា និង អក្សរសាស្ត្រជាតិ ក្នុងនោះការស្នើឱ្យបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ ក៏ជាអាទិភាពមួយផងដែរ។ តាំងពីពេលនោះរហូតមកដល់ឆ្នាំ២០០៧នេះ ចំណុចនៃអនុសាសន៍ នេះក៏បានសម្រេចជារូបរាងពិតប្រាកដ។ ខ្ញុំព្រះករុណាខ្ញុំសង្ឃឹមយ៉ាងមុតមាំថា លទ្ធផលនៃសិក្ខាសាលានេះគឺជាកត្តាមួយ ជំរុញឱ្យគណៈកម្មាធិការជាតិភាសាខ្មែររបស់យើងមានកម្លាំង និង ថាមពលសម្រេចបាននូវកិច្ចការដ៏សំខាន់ៗរបស់ខ្លួន យ៉ាងពិតប្រាកដ។ ខ្ញុំព្រះករុណាខ្ញុំសង្ឃឹមយ៉ាងជាក់ថា យើងទាំងអស់គ្នានឹងមានឯកភាពខាងសំណេរក្នុងវិស័យអក្សរសាស្ត្រខ្មែរ ហើយវិស័យអក្សរសាស្ត្រខ្មែរនឹងមានការរីកចម្រើនជាលំដាប់សម្រាប់គ្រប់បច្ចេកស័ព្ទជំនាញនានា និង ការសិក្សាអប់រំ។

ខ្ញុំព្រះករុណាខ្ញុំសុំស្នើដល់ឯកឧត្តម លោកជំទាវ លោកសាស្ត្រាចារ្យបណ្ឌិត អស់លោក លោកស្រី អ្នកសិក្សាស្រាវជ្រាវ អ្នកនិពន្ធទាំងឡាយនៃអក្សរសាស្ត្រខ្មែរ សូមមេត្តាបន្តការស្រាវជ្រាវអក្សរសាស្ត្រខ្មែរ ដើម្បីការរីកចម្រើន និង ឯកភាពអក្សរសាស្ត្រជាតិយើង។

ខ្ញុំសូមសម្ដែងនូវទឹកចិត្តសរសើរដ៏ស្មោះអស់ពីដួងចិត្ត ចំពោះរាជបណ្ឌិតសភាកម្ពុជា ជាពិសេសលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិភាសាខ្មែរ និង គណៈកម្មការរៀបចំសិក្ខាសាលាថ្ងៃនេះ ដែលខិតខំប្រឹងប្រែងរៀបចំសិក្ខាសាលាស្ដីពី "ការរៀបចំដំណើរការនៃគណៈកម្មាធិការជាតិភាសាខ្មែរ" នេះឡើង ដើម្បីរិះរកគំនិតយោបល់ និង គោលនយោបាយល្អៗសម្រាប់អង្គប្រជុំនៃគណៈកម្មាធិការជាតិភាសាខ្មែរនៅថ្ងៃខាងមុខ។

មុននឹងបញ្ចប់ក្នុងនាមឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** និង ក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមគាំទ្រនូវគំនិត និង គោលការណ៍សំខាន់ៗនៃអង្គសិក្ខាសាលាថ្ងៃនេះ ដើម្បីជម្រាបជូនដល់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** ដែលឯកឧត្តមជាប្រធាននៃគណៈកម្មាធិការជាតិភាសាខ្មែរ ឱ្យលោកបានជ្រាប ហើយនឹងរៀបចំដំណើរការប្រជុំគណៈកម្មាធិការជាតិក្នុងពេលឆាប់ៗនេះ។

នៅទីបញ្ចប់ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពរព្រះថេរានុថេរៈគ្រប់ព្រះអង្គ និង សូមជូនពរឯកឧត្តម លោកជំទាវ លោកបណ្ឌិត លោកសាស្ត្រាចារ្យ លោក លោកស្រី អស់លោកជាវាគ្មិន ជាភ្ញៀវកិត្តិយស និងអង្គសិក្ខាសាលាទាំងមូល សូមប្រកបដោយពុទ្ធពរបួនប្រការ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសបិទអង្គសិក្ខាសាស្ដីពី "ការរៀបចំដំណើរការនៃគណៈកម្មាធិការជាតិភាសាខ្មែរ" ចាប់ពីពេលនេះទៅ។

សូមអរព្រះគុណ សូមអរគុណ !

**របាយការណ៍បូកសរុបខ្លឹមសារសិក្ខាសាលា ស្ដីពី**
**"ការរៀបចំដំណើរការនៃគណៈកម្មាធិការជាតិភាសាខ្មែរ"**
**ថ្ងៃព្រហស្បតិ៍ ទី១០ ខែឧសភា ឆ្នាំ២០០៧**
**ថ្លែងដោយ ឯកឧត្ដមសាស្ត្រាចារ្យបណ្ឌិត ស៊ុំ ឈុំប៊ុន**
**ឧបត្ថម្ភដោយ មូលនិធិកូរ៉េសម្រាប់ការសិក្សាថ្នាក់ខ្ពស់**

*- ជាបឋមខ្ញុំព្រះករុណា ខ្ញុំបាទសូមថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គ !*

*- សូមគោរពគណៈអធិបតី !*

*- សូមគោរពឯកឧត្ដម លោកជំទាវ លោកបណ្ឌិត លោកសាស្ត្រាចារ្យ លោក លោកស្រី ជាវាគ្មិន អ្នកសម្របសម្រួល ព្រមទាំងសមាជិក សមាជិកានៃអង្គសិក្ខាសាលាទាំងមូល !*

សិក្ខាសាលានេះត្រូវបានប្រកាសបើកដោយឯកឧត្ដមសាស្ត្រាចារ្យបណ្ឌិត **ស៊ឹន សំណាង** ប្រធានរាជ-បណ្ឌិតសភាកម្ពុជា ហើយបានប្រព្រឹត្តទៅអស់រយៈពេលពេញមួយថ្ងៃ។

**I-** ក្នុងនាមគណៈកម្មការរៀបចំសិក្ខាសាលា ស្ដីពី **"ការរៀបចំដំណើរការនៃគណៈកម្មាធិការជាតិភាសាខ្មែរ"** នាពេលនេះ ខ្ញុំសូមធ្វើរបាយការណ៍ជម្រាបជូនគណៈអធិបតី និង ភ្ញៀវកិត្តិយស មេត្តាជ្រាបថា អង្គសិក្ខាសាលាដែលមានរយៈពេលមួយថ្ងៃនេះ មានវាគ្មិនចូលរួមចំនួន០៦រូប អ្នកសម្របសម្រួល០៥រូប និង ភ្ញៀវចូលរួមចំនួន ៨៥រូប។ វាគ្មិន និង អ្នកចូលរួមបានពិភាក្សាប្ដូរយោបល់គ្នាយ៉ាងផុលផុសលើប្រធានបទមួយចំនួន ដូចតទៅ :

១-ឯកឧត្ដមសាស្ត្រាចារ្យបណ្ឌិត **ពុំ ម៉ល់** ធ្វើបទអន្តរាគមន៍ស្ដីពី **"ប្រវត្តិ និង ការវិវត្តទូទៅនៃភាសាខ្មែរ"**។

ឯកឧត្ដមបានបញ្ជាក់ថា :

- ភាសាមានការវិវត្តក្នុងរយៈពេលយូរ នាំឱ្យពាក្យមានការផ្លាស់ប្ដូរ ដូចករណី ពាក្យ **ម៉ាត់** បើតាមសិលាចារឹក មានន័យថា **ភ្នែក** តែមកដល់ពេលបច្ចុប្បន្ន វាមានន័យថា **មាត់**, ឯពាក្យ **ក្ញុំ** កាលពីបូរាណ មានន័យថា **ខ្ញុំបម្រើ** តែបច្ចុប្បន្ន មានន័យថា **ខ្ញុំ** (ជាបុរិសសព្វនាម)។

-យើងត្រូវញែកឱ្យដាច់គ្នារវាង **ភាសា** និង **អក្សរ** បានសេចក្ដីថា **ភាសា**ជាសូរ ឯ**អក្សរ**ជាស្នាមគំនូសសម្រាប់កត់ត្រាភាសា ។

- តាមជាតិស័ព្ទដើម ពាក្យ **សព្ទ័** និង **ស័ទ្ទ** មានន័យដូចគ្នា គឺមានន័យថា **សូរ**, តែបច្ចុប្បន្ន ពាក្យ **ស័ព្ទ** ប្រើសម្រាប់សម្គាល់ន័យថា **ពាក្យ** , ឯពាក្យ **ស័ទ្ទ** ប្រើសម្រាប់សម្គាល់ន័យថា **សូរ**។

- វៀតណាមបានប្ដូរអក្សរដើមរបស់គេ ដែលមានរូបរាងជាអក្សរចិន មកប្រើតួអក្សរឡាតាំងជំនួសវិញរហូតដល់សព្វថ្ងៃ។ ចំណែកឯអក្សរខ្មែរក៏មានការវិវត្តជាហូរហែតាំងពីដើមរៀងមក ទាំងសញ្ញាស្រៈ និង សញ្ញាព្យញ្ជនៈ ឯភាសាក៏មានការវិវត្តផងដែរ។

-ភាសាខ្មែរមិនមែនជាកូនភាសាសំស្ក្រឹត-បាលីទេ  ទោះបីនៅក្នុងវចនានុក្រមខ្មែរមានពាក្យខ្ចីពីសំស្ក្រឹត-បាលីប្រមាណ ៣១,៣៦%ក៏ដោយ។ ឯពាក្យ **ប្រពៃណី** ឯកឧត្តមបញ្ជាក់ថា ពីដើម គេអានថា **ប្រ-ពៃ-នី** មិនអានថា **ប្រ-ពៃ-ណី** ទេ ។

នៅចុងបញ្ចប់ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ក៏បានបន្ថែមថា សម្តេចសង្ឃរាជ **ជួន ណាត** មានគោលរបស់លោកក្នុងការសរសេរ : បើពាក្យឫសសរសេរត្រួត ពាក្យកម្លាយក៏សរសេរត្រួត តែមិនមែនទាំងអស់ទេ ព្រោះមានសរសេរវាយជាច្រើនដែរ។ ឯកឧត្តមក៏បានស្នើផងដែរ ឱ្យរក្សាក្បួនសំណេរខ្លះផង កុំកែប្រែសំណេរលឿនពេក។

**២**-ឯកឧត្តម **សូ មុយឃៀង** ធ្វើបទអន្តរាគមន៍ស្តីពី "**ប្រវត្តិ និង ការវិវត្តនៃភាសាខ្មែរតាមរយៈខេមរយានកម្ម**"។

ឯកឧត្តមបានបង្ហាញឱ្យដឹងអំពីប្រវត្តិនៃការកកើតគណៈកម្មការខេមរយានកម្ម និង ការងាររបស់ស្ថាប័ននេះ ដោយបញ្ជាក់ថា ស្ថាប័ននេះកើតតាំងពីឆ្នាំ១៩៦៧ ហើយបន្តអត្ថិភាពរហូតមកដល់ឆ្នាំ១៩៧៥។

ឯកឧត្តមបានបង្ហាញថា :

-ក្នុងសមាជលើកទី៣ ឆ្នាំ១៩៦៧ លោក ហែល ស៊ុម ជាអ្នកផ្តើមគំនិតលើកឡើងអំពីបញ្ហានៃការប្រើភាសាខ្មែរជាយានក្នុងកម្មវិធីសិក្សា ហើយក្រសួងសិក្សាធិការក៏រៀបចំកម្មវិធីដោយយកភាសាខ្មែរជាយាននៅក្នុងឆ្នាំ១៩៦៧នោះដែរ។ ការយកភាសាខ្មែរជាយាននេះចាប់ផ្តើមពីថ្នាក់ទី៦ឡើងទៅ ដោយតម្រូវឱ្យអនុវត្តការបង្រៀនជាភាសាខ្មែរនៅមធ្យមសិក្សាបន្តជាហូរហែមក។

-អង្គការដែលស្ថិតនៅក្រោមក្រសួងសិក្សាធិការមានគណៈកម្មការខេមរយានកម្ម និង គណៈកម្មការចម្រុះភាសាខ្មែរផ្សេងៗ ដូចជា :

+ គណៈកម្មការពាក្យ

+ គណៈកម្មការវេយ្យាករណ៍

+ គណៈកម្មការជាតិអចិន្ត្រៃយ៍

+ គណៈកម្មការវប្បធម៌

+ វិទ្យាស្ថានខ្មែរ-មន

-គណៈកម្មការខេមរយានកម្មបានផុតរលត់នៅឆ្នាំ១៩៧៥ ពេលដែលរបបខ្មែរក្រហមចូលមកកាន់អំណាច។

- គណៈកម្មការខេមរយានកម្មបានបន្តភារកិច្ចនៅឆ្នាំ១៩៧៩ រហូតមកដល់បច្ចុប្បន្ន។

**មុខងារខេមរយានកម្ម**

-គណៈកម្មការឯកទេសនីមួយៗពិនិត្យសម្រេចរួចហើយ ទើបផ្តល់ឱ្យគណៈកម្មការវប្បធម៌ធ្វើការអនុម័ត ហើយបោះពុម្ពផ្សាយនៅក្នុងព្រឹត្តិប័ត្រ ឬ ទស្សនាវដ្តី និង ចងក្រងជាសៀវភៅតាមបែបខេមរយានកម្ម។

- រៀបរៀងសៀវភៅភាសាខ្មែរទូទៅសម្រាប់សាលាមធ្យមសិក្សា និង ឧត្តមសិក្សា។

- គណៈកម្មការខេមរយានកម្មសាកល្បង៥ឆ្នាំ ហើយបន្តរហូតដល់ពេលបច្ចុប្បន្ន។

- សម្រាប់ពាក្យសំស្ក្រឹត-បាលី ខេមរយានកម្មមិនមែនមិនប្រើនោះទេ តែគេរកភាពងាយស្រួលតែប៉ុណ្ណោះ ដូចជា ពាក្យ ចតុក្កោណ > ចតុកោណ , ចតុប្បាទ > ចតុបាទ ជាដើម ។

៣-លោកសាស្ត្រាចារ្យបណ្ឌិត **អ៊ុំ ច័ន** ធ្វើបទអន្តរាគមន៍ស្តីពី **"ដំណើរការនៃគណៈកម្មាធិការជាតិភាសាខ្មែរ : ទំនាក់ទំនងរវាងសកម្មភាពស្រាវជ្រាវនៃរាជបណ្ឌិតសភាកម្ពុជា និង សកម្មភាពស្រាវជ្រាវនៃគណៈ-កម្មាធិការជាតិភាសាខ្មែរ ដែលមានលេខាធិការដ្ឋានអចិន្ត្រៃយ៍នៅវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា"**

លោកសាស្ត្រាចារ្យបានលើកឡើងអំពីការបង្កើតវិទ្យាស្ថានភាសាជាតិនៅឆ្នាំ១៩៩៧ និង លើកយោបល់របស់អ្នកឯកទេសក្រុមអភិវឌ្ឍឧត្តមសិក្សា តាមរយៈគំនិតរបស់បណ្ឌិត ថោង ធៃល ថា ត្រូវមានអនុគណៈកម្មការតាមមហាវិទ្យាល័យ ។

លោកបណ្ឌិតបានបង្ហាញពីបេសកកម្មរបស់វិទ្យាស្ថានភាសាជាតិ ដែលមានដូចជា :

+ សិក្សាស្រាវជ្រាវភាសាខ្មែរ និង ភាសាមន-ខ្មែរដទៃទៀត ។
+ ចងក្រងវចនានុក្រម និង សទ្ទានុក្រម ។
+ ចាត់តាំងអង្គការតាមមហាវិទ្យាល័យនានា ដើម្បីប្រមូលបច្ចេកស័ព្ទតាមជំនាញរបស់ខ្លួនមកចងក្រងជាឯកសារ ។

លោកបណ្ឌិតបានបន្តទៀតថា :

+ គណៈកម្មាធិការជាតិភាសាខ្មែរ ត្រូវកំណត់គោលដៅច្បាស់លាស់ ។
+ យើងត្រូវកំណត់គោលការណ៍ធ្វើយ៉ាងណាដើម្បីរកចំណុចរួមមួយ ។
+ ស្វែងរកយន្តការបែបណាមួយ សម្រាប់ការអនុវត្តការងាររបស់គណៈកម្មាធិការជាតិភាសាខ្មែរ ។

៤-លោកសាស្ត្រាចារ្យបណ្ឌិត **ចន្ទ សំណព្វ** ធ្វើបទអន្តរាគមន៍ស្តីពី **"ដំណើរការនៃគណៈកម្មាធិការជាតិភាសាខ្មែរ : ទំនាក់ទំនងរវាងសកម្មភាពស្រាវជ្រាវនៃរាជបណ្ឌិតសភាកម្ពុជា និង សកម្មភាពស្រាវជ្រាវនៃគណៈ-កម្មាធិការជាតិភាសាខ្មែរ ដែលមានលេខាធិការដ្ឋានអចិន្ត្រៃយ៍នៅវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា"**

លោកសាស្ត្រាចារ្យបណ្ឌិតបានលើកឡើងនូវចំណុចមួយចំនួន :

-រាជបណ្ឌិតសភាកម្ពុជាមានវិស័យស្រាវជ្រាវទូលំទូលាយ ច្រើនវិស័យ តែគណៈកម្មាធិការជាតិភាសាខ្មែរវិញផ្តោតទៅលើភាសាខ្មែរតែមួយគត់ ។

- យើងត្រូវកែលម្អភាសា មិនគួរកាត់តម្រឹមភាសាទេ ។

- គណៈកម្មាធិការជាតិភាសាខ្មែរមានទីតាំងស្ថិតនៅវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា ប៉ុន្តែជាស្ថាប័នផ្ទាល់របស់រាជរដ្ឋាភិបាល ដូច្នេះសំណូមពរឱ្យមានឯកភាពគ្នាក្នុងការស្រាវជ្រាវ ។

-វិបត្តិអក្សរសាស្ត្រក្នុងសង្គមខ្មែរ គឺមកពីមានចលនាពីរដែលមិនសំយោគគ្នា ។

-គួរពិចារណាក្នុងការអនុម័តពាក្យខ្មែរ កុំអនុម័តដោយសំអាងតែក្រុមមនុស្ស៥០-៦០នាក់ ឬ ១០០នាក់នោះ គួរមានការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយទូទៅ ដើម្បីឱ្យសាធារណជនជួយផ្តល់មតិ ។

៥-ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **រស់ ចន្ត្រាបុត្រ** ធ្វើបទអន្តរាគមន៍ស្តីពី **"ដំណើរការនៃគណៈកម្មាធិការជាតិភាសាខ្មែរ : លំដាប់អាទិភាពនៃដំណោះស្រាយបញ្ហា និង ការបង្កើតអនុគណៈកម្មការបច្ចេកស័ព្ទ"** ។

ឯកឧត្តមបានលើកឡើងនូវចំណុចមួយចំនួន ដូចជា :

-បរិបទប្រេះឆានៅក្នុងសង្គមមាន៣ គឺទី១ : គណបក្សនយោបាយ, ទី២ : សាសនា និង ទី៣ :ទស្សនៈខ្វែងគ្នា ។ នយោបាយមិនឯកភាពនាំឱ្យមានការប៉ះពាល់ដល់ការរីកចម្រើនរបស់ភាសា ។

-ឯកឧត្តមបានលើកឡើងថា មានចរន្ត២ គឺ ទី១ : អភិរក្សនិយម និងទី២ : ចរន្តខេមរយានកម្ម ។

ដូច្នេះ តើយើងត្រូវធ្វើដូចម្តេច ដើម្បីឱ្យចរន្តទាំងពីរនេះឯកភាពគ្នាបាន ?

ឯកឧត្តមបានលើកជាសំណួរថា :

-តើបញ្ហាភាសាបាលី-សំស្ក្រឹតស្ថិតនៅត្រង់ណា ?

-តើកម្ចីភាសាបរទេសស្ថិតនៅត្រង់ណា ?

-តើគួរប្រើបច្ចេកទេសដោយបកប្រែតាមបែបភាសាបាលី-សំស្ក្រឹតឬទេ ?

ឯកឧត្តមបានផ្តល់មតិថា :

-គួរមានការបែងចែកជាគណៈកម្មការតាមឯកទេសនីមួយៗ ។

-គួររៀបចំចងក្រងវចនានុក្រមថ្មី ដោយយកលំអានតាមវចនានុក្រមសម្តេចព្រះសង្ឃរាជ **ជួន ណាត** ។

៦-ឯកឧត្តម **ឈន អៀម** ធ្វើបទអន្តរាគមន៍ស្តីពី **"ដំណើរការនៃគណៈកម្មាធិការជាតិភាសាខ្មែរ : លំដាប់អាទិភាពនៃដំណោះស្រាយបញ្ហា និង ការបង្កើតអនុគណៈកម្មការបច្ចេកស័ព្ទ" ។**

ឯកឧត្តមបានលើកឡើងនូវចំណុចសំខាន់ៗមួយចំនួន ដូចតទៅ :

-ពីមុនមក ការសរសេរអក្ខរាវិរុទ្ធតាមវត្តអារាមមិនមានឯកភាពគ្នាទេ ។

-ប្រវត្តិនៃការកកើតវចនានុក្រមតាំងពីឆ្នាំ១៩១៥ ដោយស្នាព្រះហស្តសម្តេចព្រះសង្ឃរាជ **ជួន ណាត** ។

-ការបោះពុម្ព និង ផ្សព្វផ្សាយវចនានុក្រមនៅមានកម្រិតនៅឡើយ ។

-វចនានុក្រមសម្តេចព្រះសង្ឃរាជ សម្បូរដោយពាក្យបាលី ។

-គួរជំរុញការត្រួតពិនិត្យការសរសេរអក្ខរាវិរុទ្ធឱ្យបានត្រឹមត្រូវ និង មានវិធានការណែនាំជាមុនចំពោះការសរសេរអក្សរលើផ្លាកសញ្ញា ឬ ឃីហោផ្សេងៗ ។

-ចំពោះការបកប្រែបច្ចេកស័ព្ទពីភាសាអង់គ្លេសដោយប្រើធាតុភាសាបាលី-សំស្ក្រឹត គប្បីឱ្យមានអ្នកចេះភាសាបាលី-សំស្ក្រឹតចូលរួមផង ដើម្បីកុំឱ្យភ្លាត់ខុស ។

**II-** ក្រោយពីបានដំណើរការពេញមួយថ្ងៃមក អង្គសិក្ខាសាលាប្រមូលបានអនុសាសន៍មួយចំនួន ដូចខាងក្រោម :

១-ស្នើសុំឱ្យគណៈកម្មាធិការជាតិភាសាខ្មែររៀបចំគោលការណ៍ច្បាប់របស់ខ្លួនជាមុន ដូចជា លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និង យន្តការនានា ដើម្បីដំណើរការការងារ និង បែបបទនៃការប្រជុំរបស់គណៈ-កម្មាធិការជាតិភាសាខ្មែរ ។

២-នៅក្នុងបទបញ្ជាផ្ទៃក្នុងនៃគណៈកម្មាធិការជាតិភាសាខ្មែរ ត្រូវកំណត់គោលការណ៍ជាមូលដ្ឋានមួយ

ចំនួន ដូចជា ការកំណត់ក្បួនខ្នាតវេយ្យាករណ៍ ស្វែងរកឯកភាពក្នុងការសរសេរពាក្យ ការប្រើប្រាស់សញ្ញាផ្សេងៗ ដូចជា ចំណុច (.), ក្បៀស (,), ចំណុចក្បៀស (;)....។

៣-គណៈកម្មាធិការជាតិភាសាខ្មែរ ត្រូវបង្កើតអនុគណៈកម្មការបច្ចេកទេសមួយចំនួនតាមតម្រូវការចាំបាច់ ដើម្បីឯកភាពនិងអភិវឌ្ឍន៍ភាសាខ្មែរ ប្រមូលពាក្យបច្ចេកទេសនានាតាមស្ថាប័នគ្រឹះស្ថានសិក្សាទាំង-ឡាយ មកពិនិត្យកែតម្រូវ និង បង្កើតពាក្យថ្មីដែលចាំបាច់ ។

៤-រាល់លទ្ធផលដែលគណៈកម្មាធិការជាតិភាសាខ្មែរអនុម័តរួចហើយត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ ។

៥-គណៈកម្មាធិការជាតិភាសាខ្មែរត្រូវបង្កើតអនុគណៈកម្មការមួយដែលមានភារកិច្ចត្រួតពិនិត្យលើបដាពាណិជ្ជកម្មនានា និង ការបោះពុម្ពផ្សាយសៀវភៅផ្សេងៗ ។

៦-គណៈកម្មាធិការជាតិភាសាខ្មែរ ត្រូវបង្កើតអនុគណៈកម្មការប្រមូលរៀបរៀង និង អនុម័តបន្តវចនា-នុក្រមសម្តេចសង្ឃរាជ ជួន ណាត ។

៧-ពេលដែលគណៈកម្មាធិការជាតិភាសាខ្មែររៀបចំធ្វើសិក្ខាសាលា ឬ សន្និសីទ ត្រូវអញ្ជើញលោកគ្រូអ្នកគ្រូពីគ្រប់សាលារៀន( គ្រូបង្គោល និង គ្រូបច្ចេកទេសភាសាខ្មែរ) មកចូលរួមស្តាប់ ឬ ផ្តល់មតិ ។

៨-សុំឱ្យការប្រជុំ ឬ សន្និសីទ ឬ សិក្ខាសាលានៃគណៈកម្មាធិការជាតិភាសាខ្មែរ មានការចាក់ផ្សាយតាមវិទ្យុ និង ទូរទស្សន៍គ្រប់ពេល ។

**III-** ដើម្បីដំណើរការគណៈកម្មាធិការជាតិភាសាខ្មែរឱ្យរលូន និង មានសន្ទុះអភិវឌ្ឍប្រកបដោយនិរន្តរភាព និង លទ្ធផលប្រកបដោយផ្លែផ្កាល្អប្រសើរ យើងនឹងពិចារណារៀបចំគោលការណ៍ និង យន្តការប្រតិបត្តិការងារនៃគណៈកម្មាធិការជាតិភាសាខ្មែរ ដូចខាងក្រោមនេះ :

**១-គណៈកម្មាធិការជាតិភាសាខ្មែរមានភារកិច្ចកំណត់គោលការណ៍, បទបញ្ជាផ្ទៃក្នុង, រៀបចំយន្តការ និង អនុម័តសម្រេចលទ្ធផល ដែលអនុគណៈកម្មាការនានាបានដាក់ជូន ។**

**២-គណៈកម្មាធិការជាតិភាសាខ្មែរនឹងរៀបចំលេខាធិការដ្ឋាន ដើម្បីជួយការងារ រួមមាន :**

-ផ្នែក រដ្ឋបាល

-ផ្នែក ហិរញ្ញកិច្ច

-ផ្នែក ទស្សនាវដ្តី និង បោះពុម្ពផ្សាយ

-ផ្នែក ទំនាក់ទំនងជាមួយអាជ្ញាធរ ។

**៣-ការបង្កើតគណៈកម្មការនានាមួយចំនួនដូចខាងក្រោម :**

-គណៈកម្មការពិនិត្យ និង ឯកភាពអក្ខរាវិរុទ្ធខ្មែរ ។

-គណៈកម្មការរៀបរៀង និង អភិវឌ្ឍន៍វចនានុក្រមភាសាខ្មែរ ។

-គណៈកម្មការត្រួតពិនិត្យអត្ថបទបកប្រែ និង បោះពុម្ពផ្សាយ ។

-គណៈកម្មការរៀបចំ និង អភិវឌ្ឍន៍ពាក្យបច្ចេកទេសក្នុងវិស័យព័ត៌មានវិទ្យា ។

-គណៈកម្មការឯកភាពបច្ចេកស័ព្ទតាមមុខជំនាញនានាជាច្រើនទៀត...។

ដើម្បីបម្រើតម្រូវការនៃការអភិវឌ្ឍភាសាខ្មែរឱ្យបានសមស្របតាមតម្រូវការនៃការប្រើប្រាស់ភាសាក្នុងសង្គមជាតិ។

**៤-សំណូមពរបង្កើតមូលនិធិទ្រទ្រង់ភាសាខ្មែរ**

នៅទីបញ្ចប់នៃរបាយការណ៍បូកសរុបនេះ ក្នុងនាមគណៈកម្មការរៀបចំអង្គសិក្ខាសាលានាថ្ងៃនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ លោកបណ្ឌិត លោកសាស្ត្រាចារ្យ លោក លោកស្រីជាវាគ្មិន ដែលបានចំណាយពេលវេលាខិតខំស្រាវជ្រាវ និង ធ្វើបទអន្តរាគមន៍ផ្តល់គំនិតនិងវិធីផ្សេងៗសម្រាប់ការរៀបចំដំណើរការនៃគណៈកម្មាធិការជាតិភាសាខ្មែរ និង សូមថ្លែងអំណរគុណចំពោះភ្ញៀវកិត្តិយសទាំងអស់ ដែលបានអញ្ជើញមកចូលរួមបញ្ចេញមតិយ៉ាងផុលផុស ដើម្បីបានជាគំនិតយោបល់ និង បានជាទិន្នន័យ សម្រាប់សម័យប្រជុំពេញអង្គលើកទី១របស់គណៈកម្មាធិការជាតិភាសាខ្មែរ ដែលនឹងប្រព្រឹត្តទៅនាពេលខាងមុខ ក្រោមអធិបតី-ភាពរបស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ជាប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ។

សូមគោរពជូនពរដល់គណៈអធិបតី ភ្ញៀវកិត្តិយស សមាជិក សមាជិកាអង្គសិក្ខាសាលា សូមប្រកបដោយពុទ្ធពរប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

***សូមអរព្រះគុណ និង សូមអរគុណ!***

# កម្មវិធីសិក្ខាសាលា

## ស្តីពី

## "ការរៀបចំដំណើរការគណៈកម្មការបច្ចេកទេស នៃគណៈកម្មាធិការជាតិភាសាខ្មែរ"

## ថ្ងៃពុធ ទី០៥ ខែធ្នូ ឆ្នាំ២០០៧

* ម៉ោង ៧.៣០ -៨ ព្រឹក - ចុះឈ្មោះអ្នកចូលរួម

* ម៉ោង ៨.៣០ - គោរពភ្លេងជាតិ

* ម៉ោង ៨.៣០-៨.៤៥ - **បើកកម្មវិធី :**

លោកជំទាវសាស្ត្រាចារ្យបណ្ឌិត **ខ្លូត ធីតា** អនុប្រធានរាជបណ្ឌិតសភាកម្ពុជា និង ជាសមាជិកគណៈកម្មាធិការជាតិភាសាខ្មែរ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម សាស្ត្រាចារ្យបណ្ឌិត **ស៊ន សំណាង** ប្រធានរាជបណ្ឌិតសភាកម្ពុជា និង ជាទីប្រឹក្សា គណៈកម្មាធិការជាតិភាសាខ្មែរ

* ម៉ោង ៩.០០-៩.២០ - វាគ្មិន : ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត អ៊ឹម ច័ន

- ប្រធាបទ : "***អក្ខរាវិរុទ្ធក្នុងភាសាខ្មែរ***"

- អ្នកសម្របសម្រួល : ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ញ៉ុំ ម៉ល់

* ម៉ោង ៩.២០-០៩.៤០ - វាគ្មិន : ឯកឧត្តមសាស្ត្រាចារ្យវេជ្ជបណ្ឌិត សំ សោភាន់

- ប្រធានបទ : "***ការបង្កើតពាក្យនិងកម្ចីពាក្យ***"

- អ្នកសម្របសម្រួល : ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ញ៉ុំ ម៉ល់

* ម៉ោង ០៩.៤០-១០.០០ - សម្រាកពិសាភេសជ្ជៈ

* ម៉ោង ១០.០០-១០.២០ - វាគ្មិន : លោកសាស្ត្រាចារ្យ សុខ កុសល

-ប្រធានបទ : "***បច្ចេកស័ព្ទទាក់ទងនឹងមុខជំនាញផ្សេងៗនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ***"

- អ្នកសម្របសម្រួល : ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ស៊ុំ ឈុំប៊ុន

* ម៉ោង១០.២០-១០.៤០ - វាគ្មិន : លោក **ឃួន ខិចិត្រ**

-ប្រធានបទ : "***ការប្រើប្រាស់ភាសាខ្មែរ ក្នុងប្រព័ន្ធផ្សព្វផ្សាយ***"

- អ្នកសម្របសម្រួល : ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ស៊ុំ ឈុំប៊ុន

* ម៉ោង១០.៤០-១១.០០ - សំណួរពិភាក្សា

* ម៉ោង ១១.០០-១៣.០០ - សម្រាក ពិសាអាហារថ្ងៃត្រង់

* ម៉ោង ១៣.០០-១៣.២០ - វាគ្មិន : ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ហ៊ាន សាហ៊ីប**

  - ប្រធានបទ : "***បច្ចេកស័ព្ទនៅក្នុងវចនានុក្រមសេដ្ឋកិច្ច***"

  - អ្នកសម្របសម្រួល : ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **អ៊ីុច ច័ន**

* ម៉ោង ១៣.២០-១៣.៤០ - វាគ្មិន : លោក **ខួន ខ៉ាន់ចន្ធី**

  - ប្រធានបទ :"***ការប្រមូលទិន្នន័យទាក់ទងនឹងបច្ចេកស័ព្ទ***"

  - អ្នកសម្របសម្រួល : ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **អ៊ីុច ច័ន**

* ម៉ោង ១៣.៤០-១៤.០០ - វាគ្មិន : លោកសាស្ត្រាចារ្យបណ្ឌិត **ខៀវ កុសល**

  - ប្រធានបទ : "***ការប្រើប្រាស់ពាក្យនៃភាសាខ្មែរក្នុងការតែងនិពន្ធ***"

  - អ្នកសម្របសម្រួល : ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **អ៊ីុច ច័ន**

* ម៉ោង ១៤.០០-១៤.២០ - សម្រាកពិសាភេសជ្ជៈ

* ម៉ោង ១៤.២០-១៥.៣០ - កិច្ចពិភាក្សានិងអនុសាសន៍

  - ដឹកនាំដោយ ឯកឧត្តមអនុប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ

* ម៉ោង ១៥.៣០ - **បិទកម្មវិធី :**

  - របាយការណ៍បូកសរុបរបស់ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ស៊ុំ ឈុំប៊ុន** អគ្គលេខាធិការនៃគណៈកម្មាធិការជាតិភាសាខ្មែរ

  - សុន្ទរកថាបិទរបស់ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ព្រុំ ម៉ល់** អនុប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ទីស្តីការគណៈរដ្ឋមន្ត្រី
គណៈកម្មាធិការជាតិភាសាខ្មែរ
**លេខាធិការដ្ឋានអចិន្ត្រៃយ៍ : វិទ្យាស្ថានភាសាជាតិ**
**នៃរាជបណ្ឌិតសភាកម្ពុជា**

Comité National de la Langue Khmère
Secrétariat permanent : Institut de la Langue
Nationale de l'Académie Royale du Cambodge

ទូរស័ព្ទ : ០៩២ ៨៩២ ៣៤៣, ០១៦ ៩៤៧ ៤២១ , ទូរសារ : ០២៣ ៩៨៣ ៨៧១, E-mail: prummoal@yahoo.com

# សុន្ទរកថា

**របស់ជំទាវសាស្ត្រាចារ្យបណ្ឌិត ខ្លួត ធីតា អនុប្រធានរាជបណ្ឌិតសភាកម្ពុជា និង ជាសមាជិកគណៈកម្មាធិការជាតិភាសាខ្មែរ និង ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ស៊ឹន សំណាង ប្រធានរាជបណ្ឌិតសភាកម្ពុជា និង ជាទីប្រឹក្សាគណៈកម្មាធិការជាតិភាសាខ្មែរ ក្នុងពិធីបើកសិក្ខាសាលាស្តីពី *"ការរៀបចំដំណើរការគណៈកម្មការបច្ចេកទេសនៃគណៈកម្មាធិការជាតិភាសាខ្មែរ"***

**នាថ្ងៃពុធ ទី០៥ ខែធ្នូ ឆ្នាំ២០០៧**

- **ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គ!**
- **សូមគោរពឯកឧត្តម លោកសាស្ត្រាចារ្យ បណ្ឌិត លោក លោកស្រី នាងកញ្ញាភ្ញៀវកិត្តិយសជាទីគោរពនិងជាទីមេត្រី!**

ថ្ងៃនេះជាថ្ងៃនក្ខត្តឫក្សដ៏ប្រសើរសម្រាប់រាជបណ្ឌិតសភាកម្ពុជានិយាយដោយឡែកសម្រាប់ប្រទេសជាតិរបស់យើងនិយាយរួម ដោយយើងផ្តើមជួបជុំគ្នារវាងអ្នកជំនាញខាងអក្សរសាស្ត្រខ្មែរ ក៏ដូចជាតំណាងអ្នកស្នេហាវិស័យអក្សរសាស្ត្រខ្មែរមួយចំនួន ដើម្បីជួយគ្នារៀបចំយន្តការមួយសម្រាប់ដំណើរការគណៈកម្មការបច្ចេកទេសនៃគណៈកម្មាធិការជាតិភាសាខ្មែរ ក្នុងការជួយជំរុញនេះឱ្យមានលក្ខណៈស្តង់ដារ ។

**អង្គសិក្ខាសាលាជាទីមេត្រី!**

ប្រទេសជាតិយើងបានជួបប្រទះនូវវិបត្តិអស់រយៈកាលជាង២ទសវត្ស ដែលធ្វើឱ្យការកសាងប្រទេសលើគ្រប់វិស័យត្រូវអាក់ខាន ក្នុងនោះរួមមានវិស័យភាសានិងអក្សរសាស្ត្រផងដែរ ។ ពេលនេះ ប្រទេសយើងមានស្ថិរភាពនយោបាយនិងស្ថិរភាពសង្គម ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជាដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រមុខនិងក្រោមការជួយជ្រោមជ្រែងផ្ទាល់របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ជាប្រធានគណៈកម្មាធិការជាតិភាសាខ្មែរផងដែរ ។

ការគិតគូរឡើងវិញអំពីវិស័យភាសាខ្មែរក៏ដូចជាវិស័យអក្សរសាស្ត្រជាតិ រាជរដ្ឋាភិបាលកម្ពុជាបានតែងតាំងគណៈកម្មាធិការជាតិភាសាខ្មែរមួយឡើង ដែលជាអង្គការជាតិមួយសម្រាប់ដោះស្រាយបញ្ហាភាសានិងអក្សរសាស្ត្រខ្មែរក្នុងបំណងឈានទៅរកស្តង់ដារនាពេលបច្ចុប្បន្នក៏ដូចទៅអនាគត។ ប្រជាជន មហាជនខ្មែរបានរង់ចាំគណៈកម្មាធិការនេះជាយូរមកហើយ ជាពិសេសតាំងពីឆ្នាំ២០០០មក គឺក្រោយពេលដែលវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជាបានធ្វើសន្និសីទជាតិមួយ ស្តីពី *ការសិក្សាស្រាវជ្រាវ ឯកភាព និង អភិវឌ្ឍន៍ភាសាខ្មែរ* លើកទី១ នាថ្ងៃទី៧-៩ ខែកញ្ញា ពេលនោះសមាជិកសមាជិកានៃអង្គសន្និសីទ បានផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាលបង្កើតគណៈកម្មាធិការជាតិមួយឡើង ដើម្បីដោះស្រាយបញ្ហានានានៅក្នុងវិស័យអក្សរសាស្ត្រខ្មែរ ។

## អង្គសិក្ខាសាលាជាទីមេត្រី!

ឥឡូវនេះ យើងមានគណៈកម្មាធិការជាតិភាសាខ្មែរ ដែលបានកើតឡើងនៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៧នេះមកហើយ ។ គណៈកម្មាធិការនេះ បានរៀបចំសិក្ខាសាលាលើកទីមួយ កាលពីថ្ងៃព្រហស្បតិ៍ ទី១០ ខែឧសភា ឆ្នាំ២០០៧ ស្តីពី *ការរៀបចំដំណើរការនៃគណៈកម្មាធិការជាតិភាសាខ្មែរ*។ ការជួបជុំគ្នានាពេលនោះ គឺដើម្បីពិភាក្សាពិគ្រោះយោបល់និងផ្តល់គំនិតជាជំហានដំបូងក្នុងការស្វែងរកគន្លឹះនិងយន្តការមួយសមស្រប ដើម្បីរៀបចំដំណើរការគណៈកម្មការបច្ចេកទេសនៃគណៈកម្មាធិការជាតិភាសាខ្មែរ ។

ឆ្លៀតឱកាសនេះ ខ្ញុំព្រះករុណា នាងខ្ញុំ ក្នុងនាមតំណាងឯកឧត្តមប្រធានរាជបណ្ឌិតសភាកម្ពុជា និង ជាទីប្រឹក្សានៃគណៈកម្មាធិការជាតិភាសាខ្មែរនេះ ខ្ញុំសូមសមាជិកសមាជិកានៃអង្គសិក្ខាសាលាទាំងមូល ពិភាក្សា ពិគ្រោះយោបល់គ្នាដើម្បីស្វែងរកគន្លឹះល្អៗសម្រាប់ជួយជំរុញដំណើរការគណៈកម្មការបច្ចេកទេសនៃគណៈកម្មាធិការជាតិភាសាខ្មែររបស់យើងតទៅអនាគត ។

ខ្ញុំព្រះករុណា នាងខ្ញុំ សូមប្រកាសបើកអង្គសិក្ខាសាលាចាប់ពីពេលនេះតទៅ ។

សូមអរព្រះគុណ និង សូមអរគុណ!

# សុន្ទរកថា

## បិទសិក្ខាសាលាទី២ នៃគណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ.)

## ដោយ ឯ.ឧ. ព្រុំ ម៉ល់ អនុប្រធាន នៃ គ.ជ.ភ.ខ.

**- នៅសាលប្រជុំនៃ គ.ជ.ភ.ខ.**

**- ថ្ងៃពុធ ទី៥ ខែធ្នូ ឆ្នាំ២០០៧**

• **សូមគោរព :**

- ឯកឧត្តម
- លោកជំទាវ
- លោក
- លោកស្រី

ដែលមានវត្តមាន នៅទីនេះ ពេលនេះ ដើម្បីបញ្ចប់សិក្ខាសាលារបស់យើងទាំងអស់គ្នា ។

ខ្ញុំបានសង្កេតឃើញថា មានការប្តូរយោបល់និងបទពិសោធន៍គ្នាយ៉ាងផុសផុល ទោះជាលើកដំបូង ដែលយើងចាប់ពិគ្រោះពិភាក្សាគ្នាក៏ដោយ ។ សិក្ខាសាលាថ្ងៃនេះ ជាឱកាសផ្តល់ឱ្យយើង ដើម្បីស្វែងរកគោលការណ៍ខ្លះៗ បណ្តើរៗ ឆ្ពោះទៅរកភាពរលូននិងភាពប្រសើរ ដែលយើងមិនអាចទៅដល់ភ្លាមៗ ក្រោយពីការធ្វើដំណើរតែមួយថ្ងៃនោះឡើយ ។

មុនដំបូង ខ្ញុំសុំថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រមុខ និង ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** ជាអ្នកជួយជ្រោមជ្រែងផ្ទាល់ ដោយលោកបានបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ ដើម្បីដោះស្រាយបញ្ហាដែលកំពុងចោទក្នុងភាសាខ្មែរយើង ។

ខ្ញុំសុំថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានចំណាយពេលវេលាអស់មួយថ្ងៃ ដើម្បីរួមចំណែកក្នុងការធ្វើឱ្យភាសាខ្មែរយើងកាន់តែរីកចម្រើន ទោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី មានកិច្ចការផ្ទាល់ខ្លួន នៅកន្លែងធ្វើការរបស់ខ្លួន មមាញឹកយ៉ាងណាក៏ដោយ ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី បានជ្រាបហើយថា ភាសាខ្មែរបានរីកចម្រើនខ្លាំងណាស់ក្នុងរយៈពេលប្រហែលសាម-សែសិបឆ្នាំកន្លងមកនេះ។ បើយើងមើលកុន (ខ្សែភាពយន្ត) របស់សម្តេចឪ យើងអាចសង្កេតឃើញថា តួអង្គបាននិយាយភាសាខ្មែរលាយឡំដោយពាក្យបារាំង ពីព្រោះ នៅពេលនោះ ភាសាខ្មែរនៅខ្វះពាក្យ។ ឥឡូវនេះ យើងអាចនិយាយខ្មែរ ដោយឥតប្រើពាក្យបារាំងលាយឡំនឹងពាក្យខ្មែរទេ (លើកលែងតែមានទំនោរថ្មី ឆ្ពោះទៅរកការលាយឡំពាក្យអង់គ្លេសជាមួយពាក្យខ្មែរ ដោយឥតចាំបាច់) ។

បើយើងខ្ចីពាក្យពីភាសាបរទេសតែក្នុងករណីចាំបាច់បំផុត ហើយ ខ្ចីឱ្យត្រូវគ្នាផង ភាសាយើងនឹងមានអត្តសញ្ញាណរបស់ខ្លួន។ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ជ្រាបថា ពាក្យដែលយើងនាំគ្នា ថាជាពាក្យបាលី គឺជាពាក្យដែលបុព្វជនយើងបានបង្កើតឡើង ដោយគ្រាន់តែខ្ចីធាតុពីបាលីប៉ុណ្ណោះ ដូច្នេះ គឺជាពាក្យខ្មែរដូចពាក្យឯទៀតដែរ (ចុះភាសាយើងបានខ្ចីពាក្យពីភាសាឯទៀតជាច្រើន មាន ចិន យួន ថៃ ជាដើម ម្តេចក៏យើងមិនខំរំលឹកដូចពាក្យបង្កើតឡើងដោយប្រើធាតុបាលីផង?) ប៉ុន្តែ បើយើងយកពាក្យបារាំងឬពាក្យអង់គ្លេសច្រើនស្តែកស្តាស់

មកលាយឡំជាមួយពាក្យខ្មែរ ជនបរទេសគេនឹងសង្កេតឃើញភ្លាមថា យើងប្រើពាក្យគេ (នៅប្រទេសបារាំង ជនជាតិបារាំងខ្លះ គេបានសួរខ្ញុំថា ភាសាខ្មែរខ្វះពាក្យច្រើនដល់ប៉ុណ្ណឹងឬ? កាលបើគេបានឮខ្មែរខ្លះនិយាយភាសាខ្មែរ កូនកាត់)។

ក្រោយពីបានលូតលាស់ជាច្រើនឥតឧបមាមក ភាសាយើងបានជួបប្រទះនឹងបញ្ហាមួយចំនួន ដែលត្រូវដោះស្រាយឱ្យដំណើរការល្អឡើងវិញដូចវិស័យឯទៀតដែរ ក្រោយពីសង្គ្រាមស៊ីវិលបានបណ្តាលឱ្យមូលដ្ឋានគ្រឹះទទួលការប៉ះពាល់យ៉ាងដំណំ។

អ្នកស្នេហាអក្សរសាស្ត្រខ្មែរតែងតែទាមទារឱ្យមានគណៈកម្មាធិការជាតិភាសាខ្មែរ ដើម្បីដោះស្រាយបញ្ហាទាំងនេះ។ ឥឡូវនេះ គណៈកម្មាធិការនេះត្រូវបានបង្កើតហើយ ដោយអនុក្រឹត្យ **លេខ១៨ អនក្រ.បក ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០០៧**។ បើយើងរកឯកភាពឱ្យភាសាខ្មែរយើងបាន **កូនចៅយើងជំនាន់ក្រោយនឹងចាត់ទុកថា អនុក្រឹត្យនេះជាព្រឹត្តិការសំខាន់មួយក្នុងការរីកចម្រើននៃភាសាយើង**។

**ចំពោះព្រឹត្តិការសំខាន់ៗ ក្នុងការរីកចម្រើននៃភាសាខ្មែរ ខ្ញុំសុំរំលឹកថា :**

- **ព្រះរាជប្រកាសលេខ៦៧ ចុះថ្ងៃទី៤ ខែដេសម្ប៊្រ (គឺខែធ្នូ) ឆ្នាំ១៩១៥** បានបង្កើតក្រុមជំនុំមួយ ឱ្យធ្វើវចនានុក្រមភាសាខ្មែរ ដើម្បីឱ្យប្រជាជាតិខ្មែរមានវចនានុក្រមដូចជនជាតិជឿនលឿនក្នុងលោកដែរ។ ក្រុមជំនុំនេះបានធ្វើការអស់រយៈពេល**២៣ឆ្នាំ** រហូតដល់បានចេញជាវចនានុក្រមភាសាខ្មែរជាលើកដំបូង បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យនៅ**ឆ្នាំ១៩៣៨**។ សម្តេចព្រះសង្ឃរាជ **ជួន ណាត** បានយកព្រះទ័យទុកដាក់ជាងគេ តាំងពីព្រះអង្គនៅជាស្មៀន រហូតដល់ព្រះអង្គបានឡើងជាប្រធាន។ កិច្ចការធ្វើវចនានុក្រមនេះបានប្រព្រឹត្តទៅនៅ**វត្តឧណ្ណាលោម** ដូច្នេះ យើងអាចសន្និដ្ឋានថា កាលសម័យនោះ អ្នកប្រាជ្ញជាន់ខ្ពស់ខាងអក្សរសាស្ត្រខ្មែរសឹងសុទ្ធជាព្រះសង្ឃឬអតីតភិក្ខុសង្ឃ។
- ព្រឹត្តិការទី២នៃការរីកចម្រើននៃភាសាខ្មែរគឺការបង្កើតគណៈកម្មការបច្ចេកស័ព្ទ **ដោយប្រកាសអាររតេសេនាបតី លេខ១១៨ ចុះថ្ងៃ៤កើត ខែស្រាពណ៍ ឆ្នាំចសស័ក ព.ស.២៤៧៧ ត្រូវនឹងថ្ងៃទី១៤ ខែអ៊ូត (គឺខែសីហា) ឆ្នាំ១៩៣៤** ហៅនៅពេលនោះថា «***ក្រុមជំនុំ***» «***ដែលត្រូវជ្រើសរើសរកពាក្យខេមរ ឬពាក្យភាសា បាឡី សំស្ក្រឹត ឱ្យប្រកបនឹងពាក្យភាសាបារាំងសែស ប្រយោជន៍នឹងប្រើក្នុងកិច្ចបាឋកថា ឬសរសេរដាក់ក្នុងលិខិតផ្សេងៗ សំរាប់ប្រើក្នុងរាជការព្រះនគរ***»។ គឺក្រុមជំនុំនេះហើយ ដែលក្រោយមកត្រូវគេហៅថា «**គណៈកម្មការវប្បធម៌**» ហើយ ពាក្យថ្មីៗ ផ្សាយចេញនៅរវាងឆ្នាំ១៩៥០-១៩៧០ ត្រូវបានគេហៅថា «**ពាក្យវប្បធម៌**»។ ដោយសារគុណបុណ្យនៃគណៈកម្មការបច្ចេកស័ព្ទនេះ យើងចាប់មានពាក្យបច្ចេកទេស (តែមិនទាន់ជាពាក្យឯកទេសតាមមុខវិជ្ជានៅឡើយ) ដូចពាក្យ ***វប្បធម៌ វិទ្យាល័យ រដ្ឋាភិបាល ធនាគារ ខែមករា ខែកុម្ភៈ***។ ល។
- ព្រឹត្តិការប្រវត្តិសាស្ត្រទីពាក្នុងការរីកចម្រើនភាសាខ្មែរ គឺការបង្កើត**គណៈកម្មាធិការនៃខេមរយានកម្ម**នៅឆ្នាំ **១៩៦៧** ដែលមានសម្តេចព្រះសង្ឃរាជ **ជួន ណាត** ជាប្រធាន និង ប្រធាននៃគណៈកម្មការបច្ចេកស័ព្ទនៃមុខវិជ្ជានានាជាសមាជិក។ មុខវិជ្ជានីមួយៗមានគណៈកម្មការបច្ចេកស័ព្ទមួយ ដែលត្រូវបង្កើតពាក្យខ្មែរ

សម្រាប់សងពាក្យបារាំង ដើម្បីប្រើភាសាខ្មែរជាភាសាយាននៅមធ្យមសិក្សាជំនួសភាសាបារាំង (ភាសាខ្មែរជាភាសាយានក្នុងបឋមសិក្សា តាំងពីយូរអង្វែងមកហើយ)។ **នៅពេលនោះ ពាក្យទាំងអស់ត្រូវទទួលការអនុម័តសិន មុននឹងយកទៅប្រើប្រាស់**។

ដោយមានសង្គ្រាមស៊ីវិល និង ដោយប្រទេសកម្ពុជាត្រូវបានកាន់កាប់ដោយរបបខ្មែរក្រហម គណៈកម្មាធិការខេមរយានកម្មត្រូវបានរលាយរលត់ទៅ ហើយក្រោយមក ការបង្កើតពាក្យពុំត្រូវបានគ្រប់គ្រងដូចសម័យសម្តេចព្រះសង្ឃរាជ **ជួន ណាត** ឡើយ។ សព្វថ្ងៃនេះ ខ្មែរណាក៏ដឹងដែរថា ភាសាយើងខ្វះឯកភាពទាំងក្នុងការសរសេរពាក្យនិងក្នុងការអានពាក្យមួយចំនួន ទាំងក្នុងការបង្កើតពាក្យ ទាំងក្នុងការខ្ចីពាក្យពីភាសាបរទេស។

អ្វីៗ ដែលខ្ញុំទើបបានជម្រាបជូនជាសណ្តាប់ ជាព្រឹត្តិការសំខាន់ៗនៃការរីកចម្រើននៃភាសាខ្មែរ។ ភាសាយើងក៏មានដំណើរអភិវឌ្ឍន៍ប្រហាក់ប្រហែលនឹងភាសាឯទៀតក្នុងលោកដែរ។ **ខ្ញុំជឿជាក់ថា ភាសាយើងនឹងក្លាយជាអរិយភាសាមិនខាន គឺ ក្លាយទៅជាភាសាដែលអាចកត់ត្រាបច្ចេកវិទ្យាគ្រប់ប្រភេទបាន ដោយច្បាស់លាស់ ងាយយល់រវាងខ្មែរនិងខ្មែរ <u>បើយើងឈប់សរសេរពាក្យឬអានពាក្យប្លែកៗគ្នា និង ឈប់បង្កើតពាក្យឬខ្ចីពាក្យក្នុងភាពរប៉ាត់រប៉ាយ</u> ហើយ ខ្ញុំក៏ជឿជាក់ផងដែរថា <u>នេះជាសេចក្តីប្រាថ្នារបស់ខ្មែរយើងទាំងអស់គ្នា</u>។**

នៅទីបញ្ចប់ ខ្ញុំសុំជូនពរ សូម ឯកឧត្តម លោកជំទាវ លោក និង លោកស្រី ប្រកបនឹង សេចក្តីសុខ សេចក្តីចម្រើន អាយុយឺនយូរ ជរាបរៀងទៅ។

ខ្ញុំសុំប្រកាសបិទសិក្ខាសាលាយើងពីនាទីនេះទៅ។

សូមអរគុណ។

# របាយការណ៍បូកសរុបខ្លឹមសារសិក្ខាសាលា ស្តីពី
# "ការរៀបចំដំណើរការគណៈកម្មការបច្ចេកទេសនៃគណៈកម្មាធិការជាតិភាសាខ្មែរ"
# ថ្ងៃពុធ ទី០៥ ខែធ្នូ ឆ្នាំ២០០៧
# ថ្លែងដោយ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត អ៊ុំ ច័ន

*- ជាបឋមខ្ញុំព្រះករុណា ខ្ញុំបាទសូមថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គ !*

*- សូមគោរពគណៈអធិបតី !*

*-សូមគោរពឯកឧត្តម លោកជំទាវ លោកបណ្ឌិត លោកសាស្ត្រាចារ្យ លោក លោកស្រី ជាវាគ្មិន អ្នកសម្របសម្រួល ព្រមទាំងសមាជិក សមាជិកានៃអង្គសិក្ខាសាលាទាំងមូល !*

សិក្ខាសាលានេះត្រូវបានប្រកាសបើកដោយលោកជំទាវសាស្ត្រាចារ្យបណ្ឌិត **ខ្លួត ធីតា** អនុប្រធានរាជបណ្ឌិត្យសភាកម្ពុជា និង ជាសមាជិកគណៈកម្មាធិការជាតិភាសាខ្មែរ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ស៊ន សំណាង** ប្រធានរាជបណ្ឌិត្យសភាកម្ពុជានិងជាទីប្រឹក្សាគណៈកម្មាធិការជាតិភាសាខ្មែរ ហើយបានប្រព្រឹត្តទៅអស់រយៈពេលពេញមួយថ្ងៃ។

I- ក្នុងនាមគណៈកម្មការរៀបចំសិក្ខាសាលាស្តីពី "**ការរៀបចំដំណើរការគណៈកម្មការបច្ចេកទេសនៃគណៈកម្មាធិការជាតិភាសាខ្មែរ**" នាពេលនេះ ខ្ញុំសូមធ្វើរបាយការណ៍ជម្រាបជូនគណៈអធិបតី និង ភ្ញៀវកិត្តិយសជ្រាបថា អង្គសិក្ខាសាលាដែល មានរយៈពេលមួយថ្ងៃនេះ មានវាគ្មិនចំនួន**០៨នាក់** អ្នកសម្របសម្រួល**០៤នាក់** និង ភ្ញៀវចូលរួមចំនួន**៦២នាក់**បានឡើងបញ្ចេញមតិ ពិភាក្សា ប្តូរយោបល់គ្នាយ៉ាងផុលផុសទៅលើខ្លឹមសារមួយចំនួនដូចតទៅ :

១-បទអន្តរាគមន៍របស់ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **អ៊ុំ ច័ន** ស្តីពី "**អក្ខរាវិរុទ្ធក្នុងភាសាខ្មែរ**" ។

ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត បានលើកឡើងនូវចំណុចធំៗពីរគឺ :

**ក-បញ្ហាអក្ខរាវិរុទ្ធ**

-ការកំណត់ក្បួនខ្នាតក្នុងការធ្វើវចនានុក្រមនៅឆ្នាំ១៩៦៧ ដែលមានសម្តេចព្រះសង្ឃរាជ **ជួន ណាត** ជាប្រធានបានបង្ហាញពីការប្រើប្រាស់ស្រះពេញតួ អញ្ញត្រស័ព្ទ ដែលជាសញ្ញាខុសពីការសរសេរនិងការអាន។

-ការប្រើកិរិយាស័ព្ទ **ស្តី** ទៅជា **សម្តី** ។

-ដកស្រង់យកពាក្យពីកំណាព្យដែលជាព្រះរាជនិពន្ធនៃព្រះករុណា ព្រះបាទសម្តេចហិរញ្ញរាមាឥស្សរាបតី ព្រះអង្គ ដួង ខ្លះ, កាព្យសាស្ត្រាច្បាប់រាជនេតិ ជាព្រះរាជនិពន្ធនៃព្រះរាជសម្ភារខ្លះ, កាព្យសាស្ត្រាច្បាប់ក្រោពីនោះខ្លះ, ល្បិចចៅក្រម កើតមាននៅក្នុងរជ្ជកាលនៃព្រះបាទសម្តេចព្រះជ័យចេស្តាខ្លះ, សុភាសិត និង សុភាសិតបុរាណ

និង កាព្យនិពន្ធរបស់ព្រះអង្គខ្លះ តម្រូវឱ្យសមតាមអត្ថន័យរបស់មេកាព្យនោះដោយអន្លើៗ ធ្វើឱ្យវចនានុក្រមមានមេពាក្យទូលំទូលាយគ្រាន់បើជាងមុនបន្តិច។

-គណៈកម្មការបានស្រុះស្រួលផ្អាកការប្រើសញ្ញាអឌ្ឍចន្ទជាមួយពាក្យកំព្រា ដូចជា : កុកសក , ទូកង... ទោះបីមានគំរូសិលាចារឹកក៏ដោយ ក៏ការប្រើប្រាស់មិនបានជោគជ័យដែរ។

-ក្រសួងអប់រំបានចេញលិខិតណែនាំរបស់នាយកដ្ឋានមធ្យមសិក្សា លេខ ៤៤៦៤ ន.ម.ស-ប្រត្រ. ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៦៧ ស្ដីពីការគោរពតែអក្ខរាវិរុទ្ធប្រើជាផ្លូវការ គឺអក្ខរាវិរុទ្ធដែលមានក្នុងវចនានុក្រម។

-ការអនុវត្តជួបបញ្ហាដែលមិនមានឯកភាពគ្នា ក្រោយរបបកម្ពុជាប្រជាធិបតេយ្យរលត់ទៅ ក្រសួងអប់រំ យុវជន និង កីឡា បានចេញសារាចរណែនាំ លេខ ០៣ អយក. សរណន ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៦ ស្ដីពីការប្រើប្រាស់អក្ខរាវិរុទ្ធក្នុងលិខិតស្នាមជាផ្លូវការរាល់ការសរសេរជាភាសាខ្មែរទាំងអស់ រួមទាំងកម្មវិធីគ្រប់កម្រិត (បឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សា) ត្រូវអនុវត្តយកអក្ខរាវិរុទ្ធតាមសម្ដេចសង្ឃរាជ ជួន ណាត បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៧ របស់ពុទ្ធសាសនបណ្ឌិត្យជាគោល។

-វិទ្យាស្ថានភាសាជាតិ ទើបបានរៀបរៀងវចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ លើកទី១ ដោយយកលំនាំតាមវចនានុក្រមសម្ដេចសង្ឃរាជ ជួន ណាត ដែលមានមេពាក្យចំនួន៤១.០០០ សម្រាប់ជាគោលក្នុងការចងក្រង និង អភិវឌ្ឍវចនានុក្រមភាសាខ្មែរ។

-ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការរដ្ឋមន្ត្រី និង ជាប្រធានគណៈកម្មាធិការជាតិភាសាខ្មែរបានបញ្ជាក់ថា ការបោះពុម្ពវចនានុក្រមអក្ខរាវិរុទ្ធដែលរៀបចំឡើងដោយវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជាជាព្រឹត្តិការណ៍មួយល្អប្រសើរ សមស្របទៅនឹងគោលនយោបាយរាជរដ្ឋាភិបាលកម្ពុជា ដែលកំពុងតែយកចិត្តទុកដាក់ដល់ការអភិវឌ្ឍភាសាជាតិ ដើម្បីឱ្យមានវចនសព្ទថ្មីប្រកបដោយសម្បូរភាព សម្រាប់បំពេញសេចក្ដីត្រូវការនៅក្នុងការប្រើប្រាស់បច្ចេកពាក្យទៅតាមវិស័យផ្សេងៗនៃស្ថាប័នរដ្ឋ ជាពិសេសក្នុងផ្នែកអប់រំ។

**ខ-បញ្ហាអំណាន**

- ភាសាវិទូបង្កើតសញ្ញាមួយសម្រាប់កត់សូរមួយ តែព្យញ្ជនៈខ្មែរខ្លះ សញ្ញាតែមួយកត់សូរពីរ

-តាមមូលភាព អ-អ៊ ភាសាវិទូខ្មែរបានបង្កើតសញ្ញាបន្ថែម

-ការសរសេរ និង ការអាន ក៏ចោទជាបញ្ហាអញ្ញត្រស័ព្ទដែរ ដូចជា **អញ** អានថា **អាញ់** ...

-បញ្ហាសម្រួលដោយប្រើសញ្ញា ហ្គ-ហ្ង-ហ្ស ដើម្បីសម្គាល់សញ្ញាព្យញ្ជនៈឡាតាំង។

**២**-បទអន្តរាគមន៍របស់ឯកឧត្តមសាស្ត្រាចារ្យវេជ្ជបណ្ឌិត**សំ សោភាន់** ស្ដីពី "**ការបង្កើតពាក្យ និង កម្ចីពាក្យ** "។

ឯកឧត្តមបានលើកឡើងនូវគោលការណ៍ចំនួន១២ចំណុច រួមមាន :

១-ត្រូវរកគោលការណ៍ឯកភាពណាមួយដើម្បីអនុវត្ត។

២-គួរគោរពតាមអ្វីដែលគណៈកម្មាធិការជាតិខេមរយានកម្មបានចងក្រង ឬ គ្រាន់តែកែសម្រួលខ្លះៗ

ប៉ុណ្ណោះ ។

៣-ខាងវេជ្ជសាស្ត្រ គួរផ្អែកលើភាសា greco-latin, បារាំង, អង់គ្លេស បាលី សំស្ក្រឹតជាគោល ។

៤-គួរកុំបកប្រែវាក្យស័ព្ទបច្ចេកទេសទាំងអស់ ដូចភាសាចិន ឬ វៀតណាម ដែលបង្កឱ្យនិស្សិតមានការលំបាកក្នុងពេលទៅធ្វើ graduate , post-graduate នៅបរទេស ។

៥-គួររក្សាពាក្យដែលធ្លាប់ប្រើពីមុន ឧ. **អាប់សែ** មិនបាច់អានតាមសូរអង់គ្លេសថា **អាប់សែស** ឡើយ ។

៦-ក្នុងកម្មពាក្យ គួររក្សាសូរតាមភាសាណាដែលខ្លី ងាយអានជាភាសាខ្មែរ ។

៨-គួរតែមានពាក្យខាងវេជ្ជសាស្ត្រជាភាសាខ្មែរគ្រប់គ្រាន់ដើម្បីប្រើប្រាស់ក្នុងការអភិវឌ្ឍភាសាជាតិផង និង ក្នុងការផ្សព្វផ្សាយដល់មហាជនខ្មែរផង ។

៩-ចំពោះពាក្យធ្លាប់ប្រើរួចហើយ ហើយពុំមានឫសគល់(étymologie) ត្រឹមត្រូវ គួរសម្រួលឱ្យងាយស្តាប់ ឬ ជាពាក្យវេវចនស័ព្ទទៅវិញ ឧ. ពាក្យ **ប្រពាធនកម្ម** ទៅជា **ប្រពលព្យាបាល** ។

១០-ក្នុងវិស័យវេជ្ជសាស្ត្រ មានការបកប្រែច្រើនណាស់ហើយដែរ គួរអញ្ជើញលោកបណ្ឌិតពេទ្យទាំងនោះមកសម្របសម្រួលគ្នា ដើម្បីសម្រេចបកប្រែពាក្យយកតែមួយឱ្យមានឯកភាពគ្នា ។

១១-គណៈកម្មការយើង គួរកុំមានអត្តចរិតជ្រុលនិយមពេក ដូចជា កុំតាមបារាំងជ្រុលពេក, កុំតាមអង់គ្លេសជ្រុលពេក, កុំតាមបាលី-សំស្ក្រឹតជ្រុលពេក, កុំតាមចិត្តអត្តនោមតិជ្រុលពេក, គួរស្តាប់មតិមហាជនផង ។

១២-គួរបង្កើតព្រឹត្តិប័ត្របច្ចេកស័ព្ទឱ្យបានរហ័សដើម្បីផ្សព្វផ្សាយវាក្យស័ព្ទបច្ចេកទេស និង រង់ចាំការទិតៀន ។

**៣-** បទអន្តរាគមន៍របស់លោកសាស្ត្រាចារ្យ ***សុខ កុសល*** ស្តីពី " **បច្ចេកស័ព្ទទាក់ទងនឹងមុខជំនាញផ្សេងៗនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ** "

លោកសាស្ត្រាចារ្យបានលើកឡើងពីប្រវត្តិនៃការប្រើប្រាស់បច្ចេកស័ព្ទដែលបានបកប្រែពីភាសាបារាំងចាប់តាំងពីស.វ.ទី១៩មកម្ល៉េះ ។ លោកបានលើកនូវចំណុចមួយចំនួនដែលបានប្រើប្រាស់នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដូចជា :

-មាន១១មហាវិទ្យាល័យ( មុខជំនាញច្រើន) ធ្វើឱ្យការបកប្រែពីភាសាបារាំងមកមិនឯកភាពគ្នា ។

-ការប្រើប្រាស់បច្ចេកស័ព្ទយកពីខេមរយានកម្មនិងបកប្រែយកតាមភាសាបារាំង ។

-ការបកប្រែមិនទាន់ឯកភាពគ្នា ដោយប្រើទៅតាមមុខជំនាញរៀងៗខ្លួន ។ ការយល់ដឹងពីរចនាសម្ព័ន្ធភាសាមិនច្បាស់លាស់ នាំឱ្យការបកប្រែមិនត្រឹមត្រូវ ដែលសម្តេចសង្ឃរាជ ជួន ណាត បានហៅថា ឆ្កួតស័ព្ទ ។

<u>**សំណូមពរ**</u> : សុំឱ្យគណៈកម្មាធិការជាតិភាសាខ្មែរជួយពិនិត្យឡើងវិញនូវចំណុចខ្វះខាតមិនទាន់ឯកភាព ព្រោះការធ្វើពីមុនមិនទាន់បានត្រឹមត្រូវនៅឡើយទេ និង ជៀសវាងការបកប្រែបច្ចេកស័ព្ទពីភាសាបរទេសមកជាភាសាបាលី-សំស្ក្រឹតខ្លាំងពេក នាំឱ្យខ្មែរពិបាកអាន ។

**៤**-បទអន្តរាគមន៍របស់លោកសាស្ត្រាចារ្យ **ឃួន ទិចិត្រ** ស្តីពី "**ការប្រើប្រាស់ភាសាខ្មែរក្នុងប្រព័ន្ធផ្សព្វផ្សាយ** " ។

លោកបានលើកឡើងនូវចំណុចសំខាន់ៗចំនួន០៤ គឺ :

**ក-ចំនួនសារព័ត៌មានផ្សាយជាភាសាខ្មែរនៅកម្ពុជាបច្ចុប្បន្ន :**

-កាសែតចំនួន ៣២២អង្គភាព

-ព្រឹត្តិប័ត្រ ចំនួន ៣៨អង្គភាព

-ទស្សនាវដ្ដី ចំនួន ១០៨អង្គភាព

-សមាគមសារព័ត៌មាន ចំនួន១៧

-ទូរទស្សន៍ ១២ប៉ុស្តិ៍

-ទូរទស្សន៍ខ្សែកាប្លិ៍ ចំនួន ៦៣ ប៉ុស្តិ៍

**ខ-អំពីធនធានមនុស្ស និង ការប្រើប្រាស់អក្ខរាវិរុទ្ធនៅក្នុងសារព័ត៌មាន :**

អង្គភាព កាសែត វិទ្យុ ទូរទស្សន៍នីមួយៗ មានអ្នកសរសេរ អ្នកអានភាសាខ្មែរ មានលក្ខណៈចម្រុះ ហើយអ្នកសារព័ត៌មានខ្លះ ដែលមានអាយុច្រើន ពួកគាត់សរសេរទៅតាមវចនានុក្រមសម្ដេចសង្ឃរាជ ជួន ណាត ឯអ្នកអានព័ត៌មានវិញ ខ្លះអានតាមបារាំង ខ្លះអានតាមអង់គ្លេស ។

**គ-តួនាទី និង អត្ថប្រយោជន៍នៃសារព័ត៌មាន :**

-ចុះផ្សាយអត្ថបទបកប្រែគតិបណ្ឌិតខាងសេដ្ឋកិច្ច ខាងនយោបាយ ច្បាប់ វប្បធម៌ សង្គមកិច្ច ។ល។

-សម្រាប់ផ្ដល់ដំណឹង បន្តដំណឹង បញ្ជូនព័ត៌មាន យោបល់ និង ផ្សព្វផ្សាយចំណេះដឹងគ្រប់បែបយ៉ាង ។

-ព័ត៌មានចំណេះដឹង អត្ថាធិប្បាយ វិចារណកថា ផ្ដល់ឱ្យប្រជាពលរដ្ឋបានជ្រាបអំពីបញ្ហា ដែលកើតឡើងជុំវិញខ្លួន។

***ឃ-ភាសាខ្មែរនៅក្នុងសារព័ត៌មាន :***

- សារព័ត៌មាន មានការរីកចម្រើនក្នុងការប្រើពាក្យពេចន៍ខ្មែរ ។
- ការសរសេរគោរពទៅតាមគោលការណ៍វចនានុក្រមសម្ដេចសង្ឃរាជ ជួន ណាត និង វចនានុក្រម អក្ខរាវិរុទ្ធ ។
- ការប្រើប្រាស់ពាក្យកម្ចីពីបរទេស ទាំងការអាននិងការសរសេរមិនទាន់មានឯកភាពគ្នានៅឡើយ ។

<u>សំណូមពរ</u> : សូមឱ្យមានក្បួនខ្នាតច្បាស់លាស់ទាំងការអាន និង ការសរសេរ ។

៦. បទអន្តរាគមន៍របស់បណ្ឌិត **ខៀវ កុសល** ស្តីពី " **ការប្រើប្រាស់ពាក្យនៃភាសាខ្មែរក្នុងការតែងនិពន្ធ** " ។

លោកបណ្ឌិតបានលើកឡើងនូវគោលការណ៍បីធំៗនៃការប្រើពាក្យក្នុងការសរសេរ គឺ :

១-ការប្រើពាក្យរបស់ប្រជាពលរដ្ឋទៅតាមតំបន់ដែលគេរស់នៅ ហើយគេសរសេរទៅតាមសូរសៀងទៅតាមសំឡេងរបស់អ្នកស្រុកតាមតំបន់ ។

២-ការប្រើពាក្យតាមវចនានុក្រមដែលមានរួចហើយ ។

៣-ការសរសេរក្នុងការតែងនិពន្ធ គឺស្របទៅលើពាក្យពេចន៍ដែលបាននិយាយសាមញ្ញ ពោលគឺសរសេរ

ទៅតាមពាក្យនិយាយ ។

ផលវិបាកកន្លងមក អ្នកនិពន្ធទាំងអស់ មានអ្នកនិពន្ធបទភ្លេង ទំនុកច្រៀង ប្រលោមលោក ទស្សនាវដ្ដី កាសែត ភាពយន្ត ជាដើម សុទ្ធតែប្រើប្រាស់ពាក្យខ្មែរខុសប្លែកពីសម័យកាលមុន និង សរសេរមិនឯកភាពគ្នា ។

**៧**-បទអន្តរាគមន៍របស់ឯកឧត្ដមសាស្ត្រាចារ្យបណ្ឌិត **ហ៊ាន សាហ៊ីប** ស្ដីពី **"បច្ចេកស័ព្ទនៅក្នុងវចនានុក្រមសេដ្ឋកិច្ច "** ។

ឯកឧត្ដមសាស្ត្រាចារ្យបណ្ឌិតបានលើកឡើងថា ក្នុងការបង្កើតបច្ចេកសព្ទសេដ្ឋកិច្ចកន្លងមក មានបីស្ថាប័នរួមគ្នា គឺ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

-ការប្រើបច្ចេកស័ព្ទសេដ្ឋកិច្ចនេះ មិនមែនជាពាក្យបង្កើតថ្មីទេ គឺជាពាក្យដែលមានស្រាប់ យើងយកមកភ្ជាប់គ្នាប្រើ ដើម្បីបំពេញកង្វះខាតពាក្យបច្ចេកទេស ដូចជា ពាក្យ **សវនកម្ម , សវនករ , អូឌីត** ។ល ។

-ការប្រើប្រាស់ពាក្យ គឺផ្លាស់ប្ដូរទៅតាមបរិបទនៃការងារ ។

**៨**. បទអន្តរាគមន៍របស់លោក **ខួន ខ៉ាន់ចន្ធី** ស្ដីពី **" ការប្រមូលទិន្នន័យទាក់ទងនឹងបច្ចេកស័ព្ទ "** ។

លោកបានលើកឡើងពីចំណុចមួយចំនួន ដូចជា :

-ការអភិរក្សឯកសារនៅក្នុងប្រព័ន្ធឌីជីថល ទៅតាមលក្ខណៈរូបនិងខ្លឹមសារនៃប្រភេទឯកសារនីមួយៗ ។

-ការបង្កើតតួអក្សរតាមប្រព័ន្ធយូនីកូដ ។

-ការប្រមូលឯកសារផ្សេងៗ វាយបញ្ចូលក្នុងកុំព្យូទ័រ ។

-ការបញ្ចូលវចនានុក្រមសម្ដេចសង្ឃរាជ ជួន ណាត ក្នុងប្រព័ន្ធកុំព្យូទ័រ ដែលថ្ងៃក្រោយអាចបង្កើតទៅជា សព្ទវចនាធិប្បាយ ។

-ការបង្កើតWebsite បញ្ចូលប្រជុំរឿងព្រេងខ្មែរគ្រប់ភាគ ទស្សនាវដ្ដីកម្ពុជសុរិយានិងអត្ថបទផ្សេងៗ ។

-ការបែងចែកតារាង នៅក្នុងការបញ្ចូលពាក្យទាំងអស់នេះក្នុងប្រព័ន្ធកុំព្យូទ័រ ដើម្បីបែងចែកជា មេពាក្យ ថ្នាក់ពាក្យ ពាក្យពន្យល់ ដើម្បីឈានទៅបង្កើតវចនានុក្រមសព្ទវចនាធិប្បាយនៅពេលក្រោយ ។

**II**-ក្រោយពីបានដំណើរការអង្គសិក្ខាសាលាពេញមួយថ្ងៃមក សមាជិក សមាជិកា បានផ្ដល់អនុសាសន៍មួយចំនួនដូចខាងក្រោម :

១- ចាត់តាំងគណៈកម្មការកែតម្រូវពាក្យពេចន៍ ឃ្លាប្រយោគទាំងឡាយ ដែលសរសេរនៅលើកញ្ចក់ទូរទស្សន៍ លើស្លាកក្រសួង មន្ទីរ និង យីហោផ្សេងៗ ។

២- គួរបើកវគ្គអប់រំអ្នកសារព័ត៌មាន វិទ្យុ ទូរទស្សន៍ ដើម្បីឱ្យពួកគេសរសេរនិងអានពាក្យបានត្រឹមត្រូវ ។

៣- ស្នើរៀបចំគណៈកម្មការបង្កើតពាក្យ អក្ខរាវិរុទ្ធ កម្ចីពាក្យ ឱ្យបានឆាប់រហ័ស ។

៤- ស្នើឱ្យស្ថាប័នផ្សព្វផ្សាយទាំងឡាយ មានកាសែត វិទ្យុ ទូរទស្សន៍ សរសេរអក្ខរាវិរុទ្ធខ្មែរឱ្យបានត្រឹមត្រូវ ។

៥- គួរជ្រើសរើសអ្នកជំនាញខាងភាសាបរទេសមកចូលរួមជាសមាជិកគណៈកម្មាធិការជាតិភាសាខ្មែរ ។

៦- សូមប្រកាន់ខ្ជាប់នូវអក្ខរាវិរុទ្ធនៃភាសាខ្មែរ ដោយយកតាមវចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត ។

៧- កាលណាគណៈកម្មាធិការជាតិភាសាខ្មែរបានរកឃើញឯកភាពនៅក្នុងការប្រើប្រាស់ពាក្យនិងសំណេរ ហើយ គណៈកម្មការនេះគួរបង្កើតច្បាប់ស្តីពីការប្រើប្រាស់ភាសា និង អក្សរខ្មែរ ។

៨- គណៈកម្មាធិការជាតិភាសាខ្មែរ និង គណៈកម្មការបច្ចេកទេស អនុគណៈកម្មការដទៃទៀតគួរមាន នីតិវិធីច្បាស់លាស់ក្នុងការពិភាក្សានិងអនុម័ត យកអក្ខរាវិរុទ្ធ ពាក្យពេចន៍ ឬ អត្ថន័យណាមួយ ។

៩- បង្កើតវេទិកាវិទ្យាសាស្ត្រ ស្តីពីភាសាជាតិ ។

១០- សូមរៀបចំវាក្យសព្ទខ្មែរឱ្យមានឯកភាពគ្នាលើសំណេរ និង សំណួរ ។

១១- គណៈកម្មការបច្ចេកទេសត្រូវពិនិត្យលើពាក្យដែលប្រើរួចមកហើយ មុននឹងបង្កើតពាក្យថ្មី ។

១២- គួរចាត់តាំងគណៈកម្មការមួយដោយឡែកសម្រាប់ពិនិត្យ តាមដាន និង តម្រង់ទិសការចងក្រង រៀបរៀងវចនានុក្រមពាក្យខ្មែរថ្មីក្តី វចនានុក្រមអង់ស៊ីក្លូប៉េឌីកក្តី ដែលអង្គភាពខ្លះបានកំពុងធ្វើ ឱ្យឆាប់បានចេញរូបរាង ហើយគួរមានការលើកទឹកចិត្តក្រុមនោះនិងទុកស្នាដៃនោះថា ជាផ្នែកមួយនៃការងាររបស់គណៈកម្មាធិការជាតិភាសាខ្មែរ ។

**III**-ដើម្បីដំណើរការគណៈកម្មាធិការជាតិភាសាខ្មែរឱ្យរលូន និង មានសន្ទុះអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ប្រកបដោយផ្លែផ្កា យើងពិចារណាពីដំណើរការរៀបចំគណៈកម្មការបច្ចេកទេសនៃគណៈកម្មាធិការជាតិភាសាខ្មែរ ដូចខាងក្រោម :

**១-ការបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិភាសាខ្មែរ**

- ផ្នែក រដ្ឋបាល
- ផ្នែក ហិរញ្ញកិច្ច
- ផ្នែក ទស្សនាវដ្តី និង បោះពុម្ពផ្សាយ
- ផ្នែក ទំនាក់ទំនងជាមួយអាជ្ញាធរ ។

**២-ការបង្កើតគណៈកម្មការបច្ចេកទេសនានាមួយចំនួនដូចខាងក្រោម :**

១-គណៈកម្មការអក្ខរាវិរុទ្ធនិងអំណាន

២-គណៈកម្មការនៃការបង្កើតពាក្យនិងកម្ពីពាក្យ

៣-គណៈកម្មការបច្ចេកស័ព្ទមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

៤-គណៈកម្មការបច្ចេកស័ព្ទវិទ្យាសាស្ត្រនយោបាយនិងការទូត

៥-គណៈកម្មការបច្ចេកស័ព្ទភាសាវិទ្យានិងអក្សរសិល្ប៍

៦-គណៈកម្មការបច្ចេកស័ព្ទវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

៧-គណៈកម្មការបច្ចេកស័ព្ទវប្បធម៌និងវិចិត្រសិល្បៈ

៨-គណៈកម្មការបច្ចេកស័ព្ទ ជីវសាស្ត្រ វេជ្ជសាស្ត្រ និង កសិកម្ម ។

នៅទីបញ្ចប់នៃរបាយការណ៍បូកសរុបនេះ ក្នុងនាមគណៈកម្មការរៀបចំអង្គសិក្ខាសាលា នាថ្ងៃនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ លោកបណ្ឌិត លោកសាស្ត្រាចារ្យ លោក លោកស្រី និង សូមថ្លែងអំណរគុណចំពោះភ្ញៀវកិត្តិយសទាំងអស់ ដែលបានអញ្ជើញមកចូលរួមនាពេលនេះ ហើយបានចូលរួមបញ្ចេញមតិយ៉ាងផុលផុស និង ជាពិសេសសូមថ្លែងអំណរគុណដ៏ខ្ពង់ខ្ពស់បំផុតចំពោះវាគ្មិន លោក លោកស្រី បានចំណាយពេលវេលាខិតខំស្រាវជ្រាវរកវិធីនិងក្បួនច្បាប់ផ្សេងៗ ដែលទាក់ទងនឹងការរៀបចំដំណើរការគណៈកម្មការបច្ចេកទេសនៃគណៈកម្មាធិការជាតិភាសាខ្មែរ ដើម្បីបានជាគំនិតយោបល់ ជាទិន្នន័យសម្រាប់សម័យដំណើរការគណៈកម្មការបច្ចេកទេសនៃគណៈកម្មាធិការជាតិភាសាខ្មែរ ។

សូមគោរពជូនពរដល់គណៈអធិបតី ភ្ញៀវកិត្តិយស សមាជិក សមាជិកាអង្គសិក្ខាសាលាទាំងអស់ សូមប្រកបដោយពុទ្ធពរប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

***សូមអរព្រះគុណ និង សូមអរគុណ !***

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខ: ០៣ អយក.សរណន

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៦

## សារាចរណែនាំ
## ស្ដីពីការប្រើប្រាស់អក្ខរាវិរុទ្ធក្នុងលិខិតស្នាមផ្លូវការ

កន្លងមក ក្រសួងបានពិនិត្យឃើញថា អង្គភាព នាយកដ្ឋាន និងមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត ក្រុងនានា ក្រោមឱវាទ ក៏ដូចជាគ្រឹះស្ថានសិក្សា សាធារណៈ និងឯកជនមួយចំនួន នៅប្រើប្រាស់អក្ខរាវិរុទ្ធពុំទាន់បានត្រឹមត្រូវទៅតាមគោលការណ៍កំណត់នៅឡើយ ។

ដើម្បីរួមចំណែកថែរក្សា ការពារ និងពង្រឹងភាសាជាតិខ្មែរ ឱ្យបានត្រឹមត្រូវ តាមក្បួនខ្នាតច្បាស់លាស់ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដល់ គ្រប់អង្គភាព នាយកដ្ឋានក្រោមឱវាទ ក៏ដូចជាគ្រឹះស្ថានសិក្សាសាធារណៈនិងឯកជនទាំងអស់ថា ៖

១. ចាប់ពីពេលនេះតទៅ រាល់ការសរសេរលិខិតស្នាមផ្លូវការជាភាសាខ្មែរទាំងអស់ រួមទាំងកម្មវិធីសិក្សា សៀវភៅសិក្សាគ្រប់កម្រិត (បឋមសិក្សា មធ្យមសិក្សា និង ឧត្តមសិក្សា) ត្រូវអនុវត្តយកអក្ខរាវិរុទ្ធតាមវចនានុក្រមសម្ដេចព្រះសង្ឃរាជ **ជួន ណាត** បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៧ របស់ពុទ្ធសាសនបណ្ឌិត្យជាគោល ។

២. សៀវភៅសិក្សាដែលបានបោះពុម្ពរួចហើយៗកំពុងសិក្សាសព្វថ្ងៃនេះ ត្រូវរក្សាទុកប្រើប្រាស់បន្តជាបណ្ដោះអាសន្នរហូតដល់មានសៀវភៅថ្មីជំនួស ។

៣. ចំពោះពាក្យមួយចំនួនតូចដែលប្រើមកយូរហើយដូចជាអ្នកខ្លះសរសេរដំរាប់ ខ្លះ ដម្រាប់ ខ្លះតំរាប់ ខ្លះតម្រាប់ ជាដើមត្រូវទុកឱ្យនៅតាមទម្លាប់ ។

ក្នុងស្មារតីនេះ ក្រសួងសូមឱ្យគ្រប់អង្គភាព នាយកដ្ឋាន ក្រោមឱវាទ ព្រមទាំងគ្រឹះស្ថានសិក្សា សាធារណៈ និងឯកជនទាំងអស់ ធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដល់មន្ត្រីរាជការ លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស ទាំងអស់ ដើម្បីអនុវត្តដោយស្មារតីទទួលខុសត្រូវនិងប្រសិទ្ធភាពខ្ពស់ ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និងកីឡា**

បណ្ឌិត កល ផេង

អាស័យដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៧ ២៥៣ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
Email: crsmeys@camnet.com.kh Web Site: www.moeys.gov.kh

# សេចក្តីសម្រេចសំខាន់ៗ
# នៃគណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ.)

គួររំលឹកថា គណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ.) ត្រូវបានបង្កើតឡើង ដោយអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៧ ដើម្បីឱ្យស្វែងរកឯកភាពជូនភាសាជាតិ ដែលបានទទួលផលប៉ះពាល់ ដោយសារសង្គ្រាមស៊ីវិលនិងការផ្លាស់ប្តូររបបគ្រប់គ្រងរដ្ឋជាបន្តបន្ទាប់។ គ.ជ.ភ.ខ.ធ្វើកិច្ចប្រជុំប្រចាំសប្តាហ៍រៀងរាល់ថ្ងៃពុធ ដើម្បីពិនិត្យ ពិភាក្សា និង អនុម័តសំណើផ្សេងៗ ចេញពីគណៈកម្មការបច្ចេកទេសរបស់ខ្លួន។

១-នៅថ្ងៃពុធ ២០-០២-០៨ គ.ជ.ភ.ខ.បានអនុម័តជាឯកច្ឆន្ទ ដោយមានសម្បទានពីសមាជិកមួយចំនួន យកអក្ខរាវិរុទ្ធជាផ្លូវការតាមវចនានុក្រមសម្តេច ជួន ណាត បោះពុម្ពឆ្នាំ១៩៦៧ (ភាគទី១) និង ១៩៦៨ (ភាគទី២)។

២-នៅថ្ងៃពុធ ០៥-០៣-០៨ គ.ជ.ភ.ខ.បានអនុម័តយល់ព្រមបង្កើតឱ្យមានអង់តែនមួយ សម្រាប់ឱ្យមហាជនដែលគ្មានវចនានុក្រម សួរអំពីអក្ខរាវិរុទ្ធដែលគេមិនចេះសរសេរ។ លោក ជួរ គារី លេខាធិការនៃ គ.ជ.ភ.ខ. ត្រូវបានចាត់ឱ្យទទួលខុសត្រូវ ឆ្លើយឆ្លងជាមួយអ្នកសួរ។ មហាជនអាចទាក់ទងនឹងអ្នកទទួលខុសត្រូវនេះ តាមទូរស័ព្ទលេខ ០១២ ២៥២ ៤៧៣ ឬ តាម E-mail: nckl_secretariat @ yahoo.com ។

៣-នៅថ្ងៃពុធ ២១-០៥-០៨ គ.ជ.ភ.ខ.បានពិគ្រោះពិភាក្សាលើធាតុ /-កម្ម / , /-ឧបនីយកម្ម / និង /-នីយកម្ម / ដែលគេប្រើនៅចុងពាក្យ ដូច បាបកម្ម , ជាតូបនីយកម្ម , សុខដុមនីយកម្ម ,...។ ដោយផ្អែកលើគណៈកម្មការវប្បធម៌ (គណៈកម្មការបង្កើតពាក្យ) សម័យសម្តេច ជួន ណាត ផង និង លើការចេះដឹងនៃសមាជិកខ្លួនផង គ.ជ.ភ.ខ.បានសម្រេចថា :

៣.១-ធាតុ /-កម្ម/ សម្គាល់សកម្មភាព/អំពើ ដូចក្នុង កសិកម្ម (សកម្មភាពរបស់អ្នកស្រែ), បាបកម្ម(អំពើបាប);
៣.២-ធាតុ /-ឧបនីយកម្ម / និង /-នីយកម្ម / អាចប្រើដើម្បីសងបច្ឆិមបទ (suffixe) /-isation/នៃភាសាបារាំង /អង់គ្លេស ឬ /-ization / នៃអង់គ្លេសអាមេរិកាំង ប៉ុន្តែ គ.ជ.ភ.ខ.បានឱ្យអាទិភាពទៅធាតុ /-នីយកម្ម/ ដែលមិនវែងពេក ;
៣.៣-"ភាវូបនីយកម្ម"មិនមែនជាធាតុដែលមានក្នុងភាសាខ្មែរទេ ពីព្រោះ "**ភាវូ** "ជាការតភ្ជាប់រវាងព្យាង្គ"**ភាព**" ខាងចុងនៃពាក្យដើមខ្លះ ដូចពាក្យ ឯក**ភាព** , សេរី**ភាព** ,... ទៅនឹងព្យាង្គខាងដើមនៃធាតុ /-**ឧប**នីយកម្ម / : ក្រោយពីមានការបូកបញ្ចូល "ឯក**ភាព**" ជាមួយ /-**ឧប**នីយកម្ម / , ព្យាង្គ "**ភាព**" បានក្លាយទៅជា "**ភាវ**", ដូច្នេះ "ឯក**ភាពុប**នីយកម្ម"ក៏ក្លាយទៅជា "ឯក**ភាវូប**នីយកម្ម" (ក៏ដូចជា "សេរី**ភាវូប**នីយកម្ម / សន្តិ**ភាវូប**នីយកម្ម ,..." ផងដែរ)។

៤-នៅថ្ងៃពុធ ២៨-០៥-០៨ គ.ជ.ភ.ខ.បានដោះស្រាយបញ្ហាទាក់ទងនឹងការសរសេរជាអក្សរខ្មែរនូវសូរបរទេសមួយចំនួន ដែលយើងតែងប្រទះតាមរយៈពាក្យកម្ចី ដោយអនុម័តយកសំណើរបស់ឯកឧត្តម បណ្ឌិត ច័ន្ទ សំណព្វ ដែលបានធ្វើការស្រាវជ្រាវដោយផ្អែកលើវចនានុក្រមសម្តេច ជួន ណាត។ សូរទាំងនោះមាន :

- [g]ដែលយើងត្រូវប្រើកន្សោមព្យញ្ជនៈ "ហ្គ" ;
- [f] ដែលយើងត្រូវប្រើកន្សោមព្យញ្ជនៈ "ហ្វ";
- [ʒ]ដែលយើងត្រូវប្រើកន្សោមព្យញ្ជនៈ"ហ្ស";
- [ʃ]ដែលយើងត្រូវប្រើកន្សោមព្យញ្ជនៈ "ស្ហ";
- [s] / [z]ដែលយើងត្រូវប្រើព្យញ្ជនៈ "ស/ស៊" ។

**ជ.ប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ**
**អនុប្រធានអចិន្ត្រៃយ៍**

លេខ ១ បោះពុម្ពចំនួន ១.០០០ ច្បាប់
បោះពុម្ពនៅរោងពុម្ព ភ្នំពេញ
ផ្ទះលេខ ២៥ ផ្លូវលេខ ៤១០ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ